# ព្រះរាជក្រម

នស/រកម/០៤០៥/០១១

## យើង

## ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៥ នាសម័យ ប្រជុំពេញអង្គ លើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្របលើ ទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង កាលពីថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

# ច្បាប់
## ស្តីពី
## ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា
## ចូលរួមក្នុងអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលរួមក្នុងអនុសញ្ញាទោលស្តីពីគ្រឿងញៀនឆ្នាំ ១៩៦១ ដែលធ្វើនៅទីក្រុងញូវយ៉ក នាថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៦១ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញានេះ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

នស.០៥០៥.១៧២

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា និងព្រះហស្តលេខា**

**ស ខេង នរោត្តម សិរីវុឌ្ឍ**

លេខ ១៥៧៣.ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ២០០៥

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ាង តាន់

7/3

# អនុសញ្ញាគោល

## ស្តីអំពី

# គ្រឿងញៀន

# ឆ្នាំ ១៩៦១

# អង្គការសហប្រជាជាតិ

# អនុសញ្ញាគោល

## ស្តីអំពី

# គ្រឿងញៀន
# ឆ្នាំ ១៩៦១

## អង្គការសហប្រជាជាតិ

ដោយមានរួមបញ្ចូលទាំងតារាង ច្បាប់ចុងក្រោយ និង សេចក្តីសំរេចដូចបានព្រមព្រៀងដោយ សន្និសីទរបស់អង្គការសហប្រជាជាតិ ក្នុងការអនុម័តអនុសញ្ញាគោល ស្តីអំពី គ្រឿងញៀន ។

អង្គការសហប្រជាជាតិ

ញូយក

ការបោះពុម្ពផ្សាយរបស់ អង្គការសហប្រជាជាតិ

ការជាវ លេខ E ៦២.X I.I

00 ៥00 P

# តារាងមាតិកា

ច្បាប់ចុងក្រោយ.......................................................................................
សេចក្តីសំរេច..........................................................................................
អនុសញ្ញាទោល ស្តីអំពី គ្រឿងញៀន ១៩៦១ ........................................................
តារាង....................................................................................................

កំណត់សំគាល់ : ផ្នែកខាងក្រោយមានផ្តល់ជូន ចន្លោះនៅផ្នែកខាងក្នុង នៃក្របខាងក្រោយសំរាប់ដាក់រាល់ការផ្លាស់ប្តូរនានាទៅលើតារាង ។

# ច្បាប់សន្និសីទរបស់អង្គការសហប្រជាជាតិចុះក្រោយសំរាប់អនុម័តអនុញ្ញាទោល
# ស្តីអំពី
# គ្រឿងញៀន

១- ក្រុមប្រឹក្សាសង្គម និងសេដ្ឋកិច្ចរបស់អង្គការសហប្រជាជាតិ តាមរយៈដំណោះស្រាយលេខ ៦៨៩ J (XXVI) ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ១៩៥៨ បានសំរេចកោះប្រជុំដោយយោងទៅមាត្រា ៦២ កថាខ័ណ្ឌទី ៤ នៃរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ ហើយដោយយោងទៅតាមបទបញ្ញត្តិ នៃសេចក្តីសំរេចមហាសន្និបាតលេខ ៣៦៦ (IV) ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៤៩ សន្និបាតពេញអង្គសំរាប់អនុម័តអនុញ្ញាទោល ស្តីអំពី គ្រឿងញៀន ជំនួសដោយលិខិតទុបករណ៍ទោល សន្និសញ្ញាពហុភាគី ដែលមាននៅក្នុងវិស័យនោះ ដើម្បីកាត់បន្ថយនូវចំនួនសន្និសញ្ញាអន្តរជាតិដែលទាក់ទងនៅនឹងការត្រួតពិនិត្យគ្រឿងញៀន ហើយដើម្បីបង្កើតបទបញ្ញត្តិសំរាប់ត្រួតពិនិត្យការកាត់បន្ថយសារធាតុគ្រឿងញៀនផៅ ។

២- សន្និសីទអង្គការសហប្រជាជាតិ ដើម្បីអនុវត្តអនុសញ្ញាទោល ស្តីអំពី គ្រឿងញៀន បានជួបប្រជុំគ្នានៅទីបញ្ជាការរបស់អង្គការសហប្រជាជាតិ ចាប់ពីថ្ងៃទី ២៤ ខែ មករា រហូតដល់ខែ មិនា ឆ្នាំ ១៩៦១ ។

៣- បណ្តារដ្ឋទាំង ៧៣ ខាងក្រោមនេះបានបញ្ជូនតំណាងរបស់ខ្លួនឱ្យចូលរួមក្នុងសន្និសីទមាន :

ប្រទេស

Afghanistan
Albania
Argentina
Australia
Bolivia
Brazil
Bulgaria
Burma
Byelorussian Soviet So-
-cialist Republic
Cambodia
Canada
Chad
Chile
China
Congo (Leopoldville)
Costa Rica
Czechoslovakia
Greece
Guatemala
Haiti
Holy See
Hungary
India
Indonesia
Iran
Iraq
Israel
Italy
Japan
Jordan
Korea, Republic of
Lebanon
LIberia
Madagascar
Mexico
Paraguay
Peru
Philippines
Poland
Portugal
Romania
Senegal
Spain
Sweden
Switzerland
Thailand
Tunisia
Turkey
Ukrainian Soviet Social-
ist Republic
Union of Soviet Social-
ist Republics
United Arab Republic

Dahomey
Denmark
Dominican Republic
El Salvador
Finland
France
Germany, Federal Re-
-public of
Ghana
Monaco
Morocco
Netherlands
New Zealand
Nicaragua
Nigeria
Norway
Pakistan
Panama
United Kingdom of
Great Britain and
Northern Ireland
United States of
America
Uruguay
Venezuela
Yugoslavia

៤- ប្រទេសមួយខាងក្រោមនេះ បានបញ្ជូនអ្នកសង្កេតការម្នាក់អោយចូលរួមក្នុងសន្និសីទគឺប្រទេសCeylon

៥- ភ្នាក់ងារជំនាញពិសេសដែលបានចូលរួមក្នុងសន្និសីទនោះ រួមមាន : អង្គការកសិកម្មម្ហូបអាហាររបស់អង្គការសហប្រជាជាតិ អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ អង្គការពលកម្មអន្តរជាតិ និង អង្គការសុខភាពពិភពលោក ។

៦- អង្គការតំណាងអន្តរជាតិ ដែលមានវត្តមាននៅក្នុងសន្និសីទនោះរួមមាន :
គណៈកម្មការកណ្តាលអចិន្ត្រៃយ៍ប្រឆាំងនឹងអាភៀន
អង្គការត្រួតពិនិត្យគ្រឿងញៀន

៧- អង្គការក្រៅរដ្ឋាភិបាលដែលមានវត្តមាននៅក្នុងសន្និសីទនោះរួមមាន:
អង្គការសន្និសីទសប្បុរសធម៌កាតូលិកអន្តរជាតិ អង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ អង្គការសហព័ន្ធមេធាវីស្ត្រីអន្តរជាតិ ។

៨- ឯកឧត្តម Safwat, នាយកការិយាល័យប្រឆាំងគ្រឿងញៀនអចិន្ត្រៃយ៍របស់សម្ព័ន្ធមិត្តអារ៉ាប់ក៏បានចូលដោយផ្ទាល់តាមរយៈការអញ្ជើញរបស់សន្និសីទនោះផងដែរ ។

៩- យោងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច និង សង្គម ដោយអនុលោមទៅតាមកថាខ័ណ្ឌ ១ និងច្បាប់នីតិវិធីដែលបានអនុម័តដោយសន្និសីទនោះ អ្នកសង្កេតការនិងអ្នកតំណាងរបស់អង្គការដែលបានរៀបរាប់ខាងលើ និង អង្គការតំណាងដែលបានចូលរួមនៅក្នុងការងារសន្និសីទគ្មានសិទ្ធិបោះឆ្នោតទេ ។

១០-សន្និសីទនោះបានបោះឆ្នោតសំរេចអោយលោក Carl Schurmann (Netherlands) ធ្វើជាប្រធាន ហើយជាអនុប្រធាន អ្នកតំណាងនៃប្រទេសខាងក្រោមនេះ :

Afghanistan
Brazil
Dahomey
France
Hungary
India
Japan
Mexico
Pakistan
Peru
Switzerland
Thailand
Turkey
United Arab Republic
United Kingdom of Great Britain and Northern Ireland
Union of Soviet Socialist Republics
United States of America

១១- លេខាធិការរបស់សន្និសីទនោះ គឺលោក G.E. Yates, ហើយ និង អនុលេខាធិការ គឺលោក Adolf Lande.

១២- សន្និសីទនោះមានសេចក្តីព្រាងលើកទី៣ នៃអនុសញ្ញាទោល ស្តីអំពី គ្រឿងញៀនដែលបានរៀបចំឡើង ដោយគណៈកម្មការ ស្តីអំពីគ្រឿងញៀនរបស់ក្រុមប្រឹក្សា និង ភាពស្មុគស្មាញនៃការអធិប្បាយដែលមាននៅទីនេះ ដោយយោងទៅតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម វាក៏មានឯកសារដទៃទៀតៗផងដែរនៅចំពោះមុខ ដែលបានរៀបចំឡើងដោយលេខាធិការ ។

១៣- សន្និសីទនោះ បានបង្កើតឡើងនូវគណៈកម្មាធិការដូចតទៅ :

គណៈកម្មការទូទៅ

ប្រធាន : ប្រធានសិន្និសីទ

គណៈកម្មាធិការពិសេស ដែលមានចែងនៅក្នុងមាត្រា ២ និង មាត្រា ៣ នៃពង្រៀងទី៣ នេះ (ទំហំរបស់សន្និសីទ និងវិធីសាស្រ្ត នៃការនាំសាធាតុបន្ថែមក្រោមការត្រួតពិនិត្យ) ។

ប្រធាន : លោក A-Tabibi (Afghanistan)

គណៈកម្មាធិការពិសេស ដែលមានចែងនៅក្នុងមាត្រា ២៥ ៣០ និង ៤០-៤៣ (ការត្រួតពិនិត្យជាទូទៅថ្នាក់ជាតិ)

ប្រធាន : លោក B. Banerji (India)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៣១-៣៤ (ការត្រួតពិនិត្យដើមអាភៀនស្រស់ និងដើមអាភៀនស្ងួតថ្នាក់ជាតិ )

ប្រធាន : លោក L.Ignacio-Pinto (Dahomey)

អនុប្រធាន ៈលោក J.Koch (Denmark)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៣៥-៣៨ ( ការត្រួតពិនិត្យស្ដីកក្ខការថ្នាក់ជាតិ)

ប្រធានៈ លោក K.Chikaraishi (Japan)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៣៩ ( ការត្រួតពិនិត្យកញ្ចប់ថ្នាក់ជាតិ)

ប្រធាន ៈ លោក B.Grinberg (Bulgaria)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ២៦ ២៧-២៩ . ២០-២១ . ៤ ( ការផ្ដល់ពត៌មានត្រូវបានគេផ្ដល់អោយតាមរយៈរដ្ឋាភិបាល ប្រព័ន្ធប៉ាន់ស្មាន និង ស្ថិតិ កាតព្វកិច្ចរបស់រដ្ឋាភិបាលជា ទូទៅ)

ប្រធាន ៈ លោក I.Rodriguez Fabregat (Uruguay)

អនុប្រធានៈ លោក J. Bertschinger (Switzerland)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ២២ (វិធានការដែលយកមកអនុវត្តដោយគណៈកម្មការនៅក្នុងករណីមិនធ្វើតាម)

ប្រធាន ៈ លោក A.Gurinovich (Byelorussian SSR)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៥-១១ . ១៣-១៩ . ២៣ ( រដ្ឋធម្មនុញ្ញ មុខងារ និង លេខាធិការអង្គការអន្តរជាតិ)

ប្រធានៈ លោក H.Blomstedt (Finland)

គណៈកម្មាធិការពិសេសដែលមានចែងនៅក្នុងមាត្រា ៤៤-៤៦ (វិធានការដោយផ្ទាល់ប្រឆាំងនឹងការរត់ពន្ធខុសច្បាប់ )

ប្រធាន ៈ លោក A.Bittencourt (Brazil)

គណៈកម្មាធិការបច្ចេកទេស

ប្រធាន ៈ លោក A.Johnson (Australia)

អនុប្រធាន ៈ លោក A. Ismael (United Arab Republic)

គណៈកម្មាធិការពង្រាង

ប្រធាន ៈ លោក R.Curran (Canada)

អនុប្រធាន ៈ លោក D.Nikolic (Yugoslavia)

គណៈកម្មាធិការសារតាំង

ប្រធាន ៈលោក G.Ortiz (Costa Rica)

១៤- ជាលទ្ធផល នៃការពិភាក្សានេះ ដូចដែលបានកត់ចូលក្នុងកំណត់ត្រាសង្ខេប នៃកំណត់ត្រាសង្ខេប និង ពេញលេញ ហើយនិងកំណត់ត្រារបស់គណៈកម្មាធិការ សន្និសីទដែលបានអនុម័ត[១] និងបើកឡើងសំរាប់ចុះហត្ថលេខាលើអនុសញ្ញាទោល ស្ដីអំពី គ្រឿងញៀន ឆ្នាំ ១៩៦១ ។ ក្រៅពីនោះ សន្និសីទបានអនុម័តទៅលើសេចក្ដីសំរេច ៥ ដែលបានបន្ថែមទៅលើច្បាប់ចុងក្រោយនេះ ។

ដើម្បីទុកជាសាក្សី អ្នកតំណាងទាំងអស់បានចុះហត្ថលេខាលើច្បាប់ចុងក្រោយនេះ ។

ធ្វើនៅទីក្រុង ញ៉ូយក ថ្ងៃទី សាមសិប ខែ មិនា ឆ្នាំ មួយពាន់ប្រាំបួនរយហុកសិបមួយ ជាភាសាចិនមួយច្បាប់ អង់គ្លេសមួយច្បាប់ បារាំងមួយច្បាប់ រុស្ស៊ីមួយច្បាប់ និង អេសប្បាញមួយច្បាប់ ដែលមានតំលៃដើមស្មើៗ គ្នា ។ អត្ថបទដើម ត្រូវតំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

[១] សន្និសីទបានកំណត់សំគាល់ឃើញថា អនុសញ្ញាដែលបានយល់ព្រមដោយគ្មានបត្យាប័នចំពោះសេចក្ដីសំរេច ឬ សេចក្ដីប្រកាសនៅក្នុងដំណោះស្រាយរបស់មហាសន្និបាតដែលទាក់ទិនណាមួយឡើយ ។

# សន្និសីទរបស់អង្គការសហប្រជាជាតិ
# បានអនុម័តសេចក្តីសំរេច ដើម្បីធ្វើការអនុម័តលើអនុសញ្ញានោល
# ស្តីអំពី
# គ្រឿងញៀន

## សេចក្តីសំរេច I

ជំនួយបច្ចេកទេសលើគ្រឿងញៀន

សន្និសីទ

ស្វាគមន៍ការបង្កើតឡើង សេចក្តីសំរេច លេខ ១៣៩៥ (XIV) ស្តីអំពី ការរៀបចំពិសេសសំរាប់ការផ្តល់ជំនួយបច្ចេកទេសក្នុងវិស័យ ត្រួតពិនិត្យគ្រឿងញៀនរបស់មហាសន្និបាត

ដោយកត់សំគាល់ថា អង្គការសហប្រជាជាតិ និង ទីភ្នាក់ងារជំនាញដែលពាក់ព័ន្ធបានផ្តល់ជូនរួចហើយនូវជំនួយដោយមានកំណត់ តាមកម្មវិធីពង្រីកជំនួយផ្នែកបច្ចេកទេស និង កម្មវិធីធម្មតានានារបស់ពួកគេ

ស្វាគមន៍ផងដែរនូវកិច្ចសហប្រតិបត្តិការរបស់អង្គការ ប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ ក្នុងការអនុវត្តន៍គំរោងជំនួយបច្ចេកទេសនានា

សំដែងនូវសេចក្តីសង្ឃឹមថា ត្រូវធ្វើអោយមានធនធានគ្រប់គ្រាន់ ដើម្បីផ្តល់ជំនួយក្នុងការប្រឆាំងនឹងចរាចរគ្រឿងញៀនដល់បណ្តាប្រទេសទាំងឡាយណាដែលមានបំណង និង ស្នើនូវធនធានទាំងនេះជាពិសេសក្នុងក្របខ័ណ្ឌទីប្រឹក្សាជំនាញ និងការហ្វឹកហ្វឺនដោយរួមបញ្ចូលទាំង វគ្គហ្វឹកហ្វឺន សំរាប់មន្ត្រីជាតិ ។

## សេចក្តីសំរេច II
## ការព្យាបាលអ្នកញៀនគ្រឿងញៀន

សន្និសីទ

រំលឹកឡើងវិញនូវបញ្ញត្តិ នៃមាត្រា ៣៨ នៃអនុសញ្ញាដែលពាក់ព័ន្ធ ការព្យាបាល និង ការអប់រំកាយសម្បទា អ្នកញៀនគ្រឿងញៀន

១- ប្រកាសថា វិធីសាស្ត្រមួយក្នុងចំណោម វិធីសាស្ត្រដែលមានប្រសិទ្ធិភាព ភាគច្រើន នៃការព្យាបាលការញៀន គឺការព្យាបាលក្នុងគ្រឹះស្ថានមន្ទីរពេទ្យមួយ ដែលមានបរិយាកាសគ្មានគ្រឿងញៀន

២- អំពាវនាវភាគីនានា ដែលមានបញ្ហាការញៀនគ្រឿងញៀនធ្ងន់ធ្ងរ និង មធ្យោបាយផ្នែកសេដ្ឋកិច្ចដើម្បីធ្វើកិច្ចការទាំងអស់នេះព្រមទាំងផ្តល់នូវឧបករណ៍ទាំងនេះដែលចាំបាច់ ។

## សេចក្តីសំរេច III

## អ្នករត់ពន្ធខុសច្បាប់

សន្និសីទ

១- អោយយកចិត្តទុកដាក់ទៅលើកំណត់ត្រាបច្ចេកទេស ស្តីអំពី អ្នករត់ពន្ធអន្តរជាតិដែលថែរក្សាទុកនៅពេលបច្ចុប្បន្ននេះ ដោយអង្គការប៉ូលីសព្រហ្មទណ្ឌអន្តរជាតិ ។

២- ផ្តល់អនុសាសន៍អោយគេបំពេញនូវកំណត់ហេតុទាំងនេះ ទៅតាមលទ្ធភាពដែលអាចធ្វើបានពីភាគីទាំងអស់ ហើយអោយប្រើប្រាស់យ៉ាងទូលំទូលាយ ដើម្បីចេញអោយប្រើនូវសេចក្តីអធិប្បាយ ស្តីអំពី អ្នករត់ពន្ធ ដោយអង្គការនោះ ។

## សេចក្តីសំរេច IV

## សមាជិកភាពក្នុងគណៈកម្មការ ស្តីអំពី គ្រឿងញៀន

សន្និសីទ

អញ្ជើញក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមអោយពិនិត្យមើលទៅលើបញ្ហា នៃការកើនឡើងក្នុងសមាជិកភាពនៃគណៈកម្មការ ស្តីអំពី គ្រឿងញៀន ស្របទៅតាមអាណត្តិនៃអនុសញ្ញានេះ និង ទស្សនៈដែល បានបញ្ចេញទៅលើបញ្ហានេះ នៅក្នុងសន្និសីទនេះក្នុងសម័យប្រជុំលើកទី ៣២ របស់ខ្លួន ។

## សេចក្តីសំរេច V

## យន្តការត្រួតពិនិត្យអន្តរជាតិ

សន្និសីទ

ដោយយល់ឃើញ អំពីសារៈសំខាន់នៃការសំរួលដល់ការរៀបចំបណ្តោះអាសន្នដែលបានផ្តល់អោយដែលមានចែងនៅក្នុងមាត្រា ៤៥ នៃអនុសញ្ញាទោល ស្តីអំពី គ្រឿនញៀននៅក្នុងឆ្នាំ ១៩៦១ ។

អញ្ជើញក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមអោយចូលរួមសិក្សាពីលទ្ធភាព នៃការចាត់វិធានការដែលធានាបាននូវការអនុវត្តន៍យ៉ាងឆាប់រហ័ស និង រលូន នៃការធ្វើអោយងាយស្រួលដល់យន្តការត្រួតពិនិត្យអន្តរជាតិ ។

# អនុសញ្ញាគោល
# ស្តីអំពី
# គ្រឿងញៀនឆ្នាំ ១៩៦១

បុព្វកថា

ភាគីទាំងឡាយ

ដែលជាប់ពាក់ព័ន្ធទៅនឹងសុខភាព សុខមាលភាពរបស់មនុស្សជាតិ

ដោយទទួលស្គាល់ថាការប្រើប្រាស់គ្រឿងញៀនក្នុងវិស័យសុខាភិបាលបន្តប្រើជាចាំបាច់ដើម្បីបំបាត់ការឈឺចាប់ និងទុក្ខវេទនាហើយបទបញ្ញត្តិគ្រប់គ្រាន់ត្រូវធ្វើឡើង ដើម្បីធានារកអោយឃើញនូវថ្នាំញៀនសំរាប់គោលបំណងនោះ ។

ដោយទទួលស្គាល់ថាការញៀនថ្នាំញៀន គឺជាគ្រោះថ្នាក់មួយដ៏ធ្ងន់ធ្ងរចំពោះបុគ្គលហើយគ្រោះថ្នាក់នេះក៏ជា ផលប៉ះពាល់ធ្ងន់ធ្ងរដល់សេកិច្ចសង្គមនិងមនុស្សជាតិផងដែរ ។

ដោយមានការភ្ញាក់រលឹកដឹងអំពីភារកិច្ចរបស់ខ្លួនដើម្បីការពារនិងប្រយុទ្ធប្រឆាំងនឹងគ្រោះថ្នាក់នេះ ។

ដោយចាត់ទុកថា វិធានការដ៏មានប្រសិទ្ធិភាពនេះប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀនតំរូវទាមទារអោយ មានសកម្មភាពសហប្រតិបត្តិការជាសកលមួយ ។

ដោយយល់ឃើញថាសកម្មភាពជាសកលនោះអំពាវនាវអោយមានកិច្ចសហប្រតិបត្តិការជាអន្តរជាតិដឹកនាំដោយគោលការណ៍តែមួយដូចគ្នា និងឆ្ពោះទៅរកគោលបំណងរួមតែមួយ ។

ដោយទទួលស្គាល់នូវសមត្ថភាពរបស់អង្គការសហប្រជាជាតិ ក្នុងវិស័យត្រួតពិនិត្យគ្រឿងញៀន និងដោយចង់អោយអង្គការអន្តរជាតិដែលពាក់ព័ន្ធ ទាំងអស់ឋិតនៅក្នុងការងារក្របខ័ណ្ឌរបស់អង្គការនោះ ។

ដោយចង់អោយបញ្ចូលអនុសញ្ញាអន្តរជាតិ ដែលអាចទទួលយកបានជាទូទៅមួយ ជំនួសសន្ធិសញ្ញាដែលមាន ស្តីអំពីគ្រឿងញៀន ដែលកំរិតដល់ថ្នាំញៀនទាំងនោះចំពោះការប្រើប្រាស់ផ្នែកវិទ្យាសាស្ត្រ និងសុខាភិបាល ហើយផ្តល់សំរាប់ការត្រួតពិនិត្យនិងសហប្រតិបត្តិការអន្តរជាតិជាបន្តដើម្បីសំរេចអោយបាននូវកម្មវត្ថុនិងគោលបំណងទាំងនោះ ។

តាមរយៈនេះ សំរេចដូចតទៅ :

## មាត្រា១

## និយមន័យ

១- និយមន័យដូចនេះត្រូវប្រើនៅក្នុងអនុសញ្ញានេះទាំងមូល វាលែងតែមានចំណុចចង្អុលបញ្ជាក់ ឬបរិបទតំរូវ :

ក- " គណៈកម្មការ" មានន័យថាគណៈកម្មការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិ ។

ខ- " កញ្ឆា" មានន័យថា ត្រួយរបស់ដើមកញ្ឆា ដែលមានផ្លែផ្កា (ដោយមិនរាបបញ្ចូលស្លឹកនិងគ្រាប់ដែលមិននៅជាប់ជាមួយត្រួយនោះឡើយ) ដែលគេមិនទាន់ចំរាញ់យកជ័រចេញ ទោះបីជាមានឈ្មោះអ្វីក៏ដោយ ។

គ- "ដើមកញ្ឆា" មានន័យថា ដើមកញ្ឆាណាក៏ដោយ ។

ឃ- "ជ័រកញ្ឆា" មានន័យថា ជ័រដែលផ្តាច់ចេញពីដើមកញ្ឆាទោះបីជានៅឆៅឬបានចំរាញ់ហើយក៏ដោយ ។

ង- "ដើមកូកា" មានន័យថា ដើមប្រភេទណាក៏ដោយនៃអំបូរអេរីត្រូស៊ីឡុន(erythroxylon) ។

ច- "ស្លឹកកូកា" មានន័យថា ស្លឹករបស់ដើមកូកាលើកលែងតែស្លឹកដែលគេបានចំរាញ់យកចេញនូវសារធាតុកាល់កាលូអ៊ីត អ៊ុកហ្គូនីនទាំងអស់ កូកាអ៊ីន និងអ៊ុកហ្គូនីនដទៃៗទៀតចេញ ។

ឆ- "គណៈកម្មាការ" មានន័យថា គណកម្មាការស្តីអំពីក្រុមប្រឹក្សាគ្រឿងញៀន ។

ជ- "ក្រុមប្រឹក្សា" មានន័យថា ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមរបស់អង្គការសហប្រជាជាតិ ។

ឈ- "ការដាំដុះ" មានន័យថា ការដាំដុះអាភៀន ដើមកូកាឬដើមកញ្ឆា ។

ញ- " ថ្នាំញៀន " មានន័យថា សារធាតុណាក៏ដោយដែលមាននៅក្នុងតារាងមួយ និង ពីរ ទោះបីជាសំយោគ ឬ ធម្មជាតិក៏ដោយ ។

ដ - " មហាសន្និបាត" មានន័យថា មហាសន្និបាតរបស់អង្គការសហប្រជាជាតិ ។

ឋ- " ជំនួញខុសច្បាប់" មានន័យថា ការដាំឬការជួញថ្នាំញៀនដោយលួចលាក់ ប្រឆាំងនឹងបទបញ្ញត្តិ នៃអនុសញ្ញានេះ ។

ឌ- "អាហរ័ណ "និង "នីហរ័ណ" មានន័យថា ក្នុងន័យលាក់កំបាំងរបស់វាថា ការបញ្ជូនថ្នាំញៀនតាមសរីរាង្គកាយពីរដ្ឋមួយទៅរដ្ឋមួយផ្សេងទៀត ពីទឹកដីមួយទៅកាន់ទឹកដីមួយផ្សេងទៀតនៅក្នុងរដ្ឋតែមួយ ។

ធ- "ការផលិត" មានន័យថា គ្រប់ដំណើរការទាំងអស់ដែលគេអាចទទួលបានថ្នាំញៀនដោយមិនសំដៅតែទៅលើការផលលិតប៉ុណ្ណោះទេ ហើយរាប់បញ្ចូលទាំងការចំរាញ់ ទាំងការបំលែងថ្នាំញៀនទាំងនោះឱ្យទៅជាថ្នាំញៀនដទៃទៀតផងដែរ ។

ណ- "អាភៀនឱសថ" មានន័យថា អាភៀនដែលបានផលលិតទៅតាមដំណើរការចាំបាច់ ដើម្បីធ្វៃវាត្រូវសំរាប់ប្រើប្រាស់ក្នុងវិស័យសុខាភិបាល ។

ត- "អាភៀន" មានន័យថា ទឹកដមរបស់ដើមអាភៀនដែលកក ។

ថ- "ដើមអាភៀន" មានន័យថា ដើមរុក្ខជាតិប្រភេទ ប៉ាប៉ាវេ ស័នីហ្វ៊េរុមអិល (Papaver Sonniferuml)

ទ- "ដើមអាភៀនស្ងួត" មានន័យថា គ្រប់ផ្នែកទាំងអស់ (លើកលែងតែគ្រាប់ចេញ) របស់ដើមអាភៀនក្រោយពេលច្រូតកាត់មក ។

ណ- "ការរៀបចំ" មានន័យថា ការច្របល់ចូលនូវវត្ថុធាតុរឹង រាវ ដែលមានផ្ទុកថ្នាំញៀន ។

ប- " ការផលិត" មានន័យថា ការបំបែកអាភៀន ស្លឹកកូកា កញ្ឆា និង ជ័រកញ្ឆាចេញពីដើមវា ដើម្បីទទួលបាននូវវត្ថុធាតុទាំងអស់នេះ ។

ផ- "តារាង១" "តារាង២" "តារាង៣" និង "តារាង៤" មានន័យថា បញ្ជីចុះចំនួនថ្នាំញៀនទាក់ទងគ្នា ឬការរៀបចំដែលបានបញ្ចូលជាឧបសម្ព័ន្ធទៅលើអនុសញ្ញានេះ នៅពេលដែលបានធ្វើវិសោធនកម្មម្តងៗ ដោយអនុលោមទៅតាមមាត្រា ៣ ។

ព- "អគ្គលេខាធិការ" មានន័យថា អគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ។

ម- " សន្និធិពិសេស" មានន័យថា ចំនួនថ្នាំញៀនដែលបានរក្សាទុកដោយរដ្ឋាភិបាលនៅក្នុងទឹកដីឬប្រទេសរបស់ខ្លួនសំរាប់គោលបំណងពិសេសរបស់រាជរដ្ឋាភិបាលនោះ និង ដើម្បីឆ្លើយតបទៅតាមកាលៈទេសៈពិសេស ហើយការបញ្ជាក់ " គោលបំណងពិសេស" នោះត្រូវបកស្រាយអោយស្របទៅតាមហ្នឹងផងដែរ ។

យ- "សន្និធិ" មានន័យថា ចំនួនថ្នាំញៀនដែលផ្ទុកក្នុងប្រទេស ឬ ដែនដីមួយហើយមានចេតនាដើម្បី :

១- ប្រើប្រាស់នៅក្នុងប្រទេស ឬ ទឹកដីនោះ សំរាប់បំរើអោយគោលបំណងផ្នែកវិទ្យាសាស្ត្រ និង សុខាភិបាល

២- ប្រើប្រាស់ក្នុងប្រទេស ឬ ទឹកដីនោះ សំរាប់ផលិតថ្នាំញៀន និង សារធាតុផ្សេងៗទៀត រឺ

៣- នាំចេញ

ប៉ុន្តែមិនរាប់បញ្ចូលចំនួនថ្នាំញៀនដែលទុកនៅក្នុងប្រទេសឬដែនដីនោះឡើយ ។

៤- តាមរយៈអ្នកលក់រាយ ឬក៏តាមរយៈអ្នកចែកចាយលក់រាយដែលមានអាជ្ញាផ្សេងទៀត និង តាមរយៈស្ថាប័ន ឬ ជនដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តន៍ មុខងារផ្នែកវិទ្យាសាស្ត្រ ឬ ផ្នែកព្យាបាលដែលមានអាជ្ញាយ៉ាងត្រឹមត្រូវ ឬ

៥- ជា "សន្និធិពិសេស"

រ- "ទឹកដី"

១- មានន័យថា ផ្នែកណាមួយនៃរដ្ឋមួយដែលចាត់ទុកថា ជាអង្គភាពដាច់ដោយឡែកមួយសំរាប់ អនុវត្តប្រព័ន្ធ ប័ណ្ណនាំចូល ឬ អាជ្ញានាំចេញដែលមានចែងនៅក្នុងមាត្រា ៣១ ។ និយមន័យនេះ មិនត្រូវ អនុវត្តចំពោះពាក្យ "ដែនដី" ដូចដែលបានប្រើនៅក្នុងមាត្រា ៤២ និង ៤៦ ទេ ។

២- សំរាប់គោលបំណងនៃអនុសញ្ញានេះ ថ្នាំញៀនត្រូវចាត់ទុកថា "ប្រើប្រាស់" នៅពេលណាគេផ្គត់ផ្គង់ ទៅអោយជនណាម្នាក់ឬសហគ្រាសណាមួយ ដើម្បីចែកចាយលក់រាយ ប្រើប្រាស់ផ្នែកសុខាភិបាល ឬ ស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ ហើយត្រូវបកស្រាយអោយត្រឹមត្រូវទៅតាមការ ប្រើប្រាស់ នោះ ។

## មាត្រា ២

## សារធាតុដែលស្ថិតក្រោមការត្រួតពិនិត្យ

១- ថ្នាំញៀនទាំងអស់ដែលមាននៅក្នុងតារាង១ ត្រូវត្រួតពិនិត្យទៅតាមគ្រប់វិធានត្រួតពិនិត្យដែលអនុវត្តចំពោះថ្នាំញៀនទាំងអស់ ដែលចិតនៅក្រោមអនុសញ្ញានេះ ហើយជាពិសេសចំពោះថ្នាំញៀនទាំងអស់ ដែលរៀបរាប់នៅក្នុងមាត្រា ៤ (ក) ១៩ ២០ ២១ ២៩ ៣០ ៣១ ៣២ ៣៣ ៣៤ និង ៣៧ លើកលែងតែ ដូចជាចំពោះវិធានការត្រួតពិនិត្យដែលគេគិតចំពោះថ្នាំញៀនដែលបានបញ្ជាក់ ។

២- ថ្នាំញៀនទាំងអស់នៅក្នុងតារាង II ត្រូវត្រួតពិនិត្យតាមវិធានការតែមួយដូចគ្នា នឹងថ្នាំញៀននៅក្នុងតារាង I ដោយលើកលែងតែវិធានការទាំងឡាយដែលមានចែងក្នុងមាត្រា ៣០ កថាខ័ណ្ឌ ២ និង ៥ ក្នុងការលក់រាយ ។

៣- ការរៀបចំថ្នាំញៀន ក្រៅពីថ្នាំញៀនទាំងនោះដែលមាននៅក្នុងតារាង៣ ត្រូវត្រួតពិនិត្យទៅតាមវិធានការតែមួយដូចថ្នាំញៀន ដែលពួកគេមានប៉ុន្តែការប៉ាន់ស្មាន់ (មាត្រា ១៩) និង ស្ថិត (មាត្រា ២០ ) ផ្សេងគ្នាពីវិធានការ ដែលអនុវត្តចំពោះថ្នាំញៀនទាំងនេះ មិនត្រូវតំរូវអោយមាននៅក្នុងករណីរៀបចំថ្នាំញៀននោះទេ ហើយមាត្រា ២៩ កថាខ័ណ្ឌ ២ (ក) និង មាត្រា ៣០ កថាខ័ណ្ឌ (ខ) (ii) មិនត្រូវអនុវត្តឡើយ ។

៤- ការរៀបចំនៅក្នុងតារាង III ត្រូវតែត្រួតពិនិត្យទៅតាមវិធានការតែមួយដូចគ្នា នឹង ការរៀបចំថ្នាំញៀននៅក្នុងតារាង II លើកលែងតែមាត្រា ៣១ កថាខ័ណ្ឌ ១ (ខ) និង ៤ ដល់ ១៥ នោះមិនត្រូវអនុវត្តឡើយ និង ចំពោះគោលបំណងប៉ាន់ស្មាន (មាត្រា ១៩) និងស្ថិត (មាត្រា ២០) ពត៌មានដែលតំរូវឱ្យមានត្រូវដាក់កំរិតទៅលើបរិមាណថ្នាំញៀនដែលប្រើនៅក្នុងការផលិតទៅតាមការរៀបចំបែបនោះ ។

៥- ថ្នាំញៀនដែលមាននៅក្នុងតារាង IV ត្រូវបានបញ្ចូលទៅក្នុងតារាង I ផងដែរ ហើយត្រូវតែត្រួតពិនិត្យទៅតាមវិធានការទាំងឡាយដែលអនុវត្តចំពោះថ្នាំញៀនដែលមាននៅក្នុងតារាងក្រោយ ៗ និង លើសពីនេះ ។

ក- ភាគីមួយត្រូវអនុម័តទៅលើវិធានការ ត្រួតពិនិត្យពិសេសទាំងឡាយណាដែលចាំបាច់ទៅតាមការយល់ឃើញរបស់ខ្លួន
ដោយមានការយល់ឃើញដល់គុណភាពថ្នាំញៀនដែលបាត់បង់ដោយ អន្លើរៗនោះក៏ត្រូវបានបញ្ចូលផងដែរ ហើយ

ខ- ប្រសិនបើតាមទស្សនៈរបស់ខ្លួន ល័ក្ខខ័ណ្ឌទូទៅនៅក្នុងប្រទេសនោះ ធ្វើអោយវាំងស្ទះមធ្យោបាយការពារសុខមាលភាព និង សុខភាពសារណៈ ភាគីនោះត្រូវហាមឃាត់ដល់ផលលិតកម្ម ការផលលិត ការនាំចូលថ្នាំញៀនចាស់ សំរាប់ប្តូរយកថ្មី ការមានជាកម្មសិទ្ធិ ឬការប្រើប្រាស់ ថ្នាំញៀនប្រភេទណាមួយ លើកលែងតែចំពោះបរិមាណដែលចាំបាច់ប្រើសំរាប់ការស្រាវជ្រាវ ផ្នែកវិទ្យាសាស្ត្រ និង សុខាភិបាលតែមួយគត់ ដោយរាប់បញ្ចូលទាំងការសាកល្បងធ្វើការព្យាបាលជាមួយថ្នាំញៀន ឋិតនៅក្រោមឬត្រូវតែត្រួតត្រា ពិនិត្យដោយផ្ទាល់ពីភាគីនោះ ។

៦- ក្រៅពីវិធានការត្រួតពិនិត្យ ដែលអនុវត្តទៅលើថ្នាំញៀនទាំងអស់នៅក្នុងតារាង I អាភៀនត្រូវឋិតនៅក្រោមបទបញ្ញត្តិទាំងឡាយនៃមាត្រា ២៣ និង ២៤ ស្លឹកកូកា ត្រូវឋិតនៅក្រោមបទបញ្ញត្តិនោះដែរនៃមាត្រា ២៦ និង ២៧ ហើយកញ្ឆាឋិតនៅក្នុងបទបញ្ញត្តិ នៃមាត្រា ២៨ ផងដែរ ។

៧- ដើមអាភៀន ដើមកូកា ដើមកញ្ឆា ដើមអាភៀនក្រៀម និង ស្លឹកកញ្ឆា ត្រូវតែត្រួតពិនិត្យទៅតាមវិធានការនីមួយៗដែលបានរៀបរាប់នៅក្នុងមាត្រា ២២ ដល់ ២៤ . ២២, ២៦ និង ២៧ . ២២ និង ២៨ . ២៥ ហើយនិងមាត្រា ២៨ ។

៨- ភាគីទាំងអស់ត្រូវប្រើប្រាស់កិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនអោយអស់កំលាំងកាយចិត្ត ដើម្បីអនុវត្តចំពោះសារធាតុទាំងឡាយដែលមិនឋិតនៅក្រោមអនុសញ្ញានេះ ប៉ុន្តែគេអាចប្រើប្រាស់ការផលិតគ្រឿងញៀនខុសច្បាប់ វិធានការនៃការត្រួតពិនិត្យបែបនេះអាចអនុវត្តបាន ។

៩- គេមិនត្រូវតំរូវអោយភាគីទាំងអស់អនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះចំពោះថ្នាំញៀនដែលគេនិយមប្រើប្រាស់ ក្នុងឧស្សាហកម្មសំរាប់គោលបំណងក្រៅពីផ្នែកវិទ្យាសាស្ត្រ រឺ សុខាភិបាល ដែលបានចែងថា:

ក- ពួកគេធានាអោយបានតាមរយះវិធីសាស្ត្រសមស្រប ខុសពីធម្មជាតិរឺតាមរយៈមធ្យោបាយដទៃទៀត ដែលគេប្រើថ្នាំញៀន ដែលមិនអាចនឹងមានការបំពានគ្រឿងញៀន រឺមានឥទ្ធិពលអាក្រក់ (មាត្រា៣ កថាខ័ណ្ឌ៣)ហើយដែលនៅក្នុងការអនុវត្តន៍ គេមិនអាចទាញយកសារធាតុដែលមាន គ្រោះថ្នាក់ ទាំងនោះមកវិញបានឡើយ ។

ខ- ពួកគេបញ្ចូលទៅក្នុងពត៌មានស្ថិតិ(មាត្រា២០)ដែលបានចែងដោយផ្តល់អោយពួកគេនូវបរិមាណថ្នាំញៀន នីមួយៗដែលបានប្រើប្រាស់។

## មាត្រា៣

## ការផ្លាស់ប្តូរទំហំនៃការត្រួតពិនិត្យ

១- កន្លែងដែលភាគីមួយរឺអង្គការសុខភាពពិភពលោកមានពត៌មាន ដែលតាមទស្សនៈផ្ទាល់ខ្លួនអាចតំរូវអោយមានការធ្វើវិសោធនកម្មលើតារាងណាមួយខ្លួនត្រូវប្រកាសជូនដំណឹងដល់អគ្គលេខាធិការហើយផ្តល់នូវពត៌មានដែលឆ្លើយតបនិងការជូនដំណឹងនោះ។

២- អគ្គលេខាធិការត្រូវបញ្ជូនពត៌មានបែបហ្នឹង ហើយនិងពត៌មានដទៃទៀតដែលគិតថាទាក់ទងនិងគ្នាអោយទៅគ្រប់ភាគីទៅគណៈកម្មការនិងទីកន្លែងដែលភាគីមួយធ្វើការជូនដំណឹងទៅអោយអង្គការសុខភាពពិភពលោក។

៣- កន្លែងដែលការជូនដំណឹងមួយ ជាប់ទាក់ទិនទៅនឹងសារធាតុមួយមិនទាន់មាននៅឡើយនៅក្នុងតារាង I រឺនៅក្នុងតារាង II ។

(i) ភាគីទាំងអស់ត្រូវពិនិត្យពិចែរមើលលទ្ធភាពនៃការអនុវត្តន៍បណ្តោះអាសន្នចំពោះសារធាតុនេះ គ្រប់វិធានការត្រួតពិនិត្យទាំងអស់ដែលអនុវត្តទៅលើថ្នាំញៀនក្នុងតារាង I ដោយមានពត៌មានដែលគេរកបាន។

(ii) ដោយរង់ចាំសេចក្តីសំរេចរបស់ខ្លួន ដូចដែលបានចែងនៅក្នុងអនុកថាខ័ណ្ឌ៧នៃកថាខ័ណ្ឌនេះ គណៈកម្មការអាចសំរេចអោយភាគីទាំងឡាយអនុវត្តចំពោះសារធាតុនោះជាបណ្តោះអាសន្ន នូវវិធានការត្រួតពិនិត្យបែបនោះជាបណ្តោះអាសន្នចំពោះសារធាតុដែលមានបញ្ហា ។

(iii) ប្រសិនបើអង្គការសុខភាពពិភពលោកដឹងថា សារធាតុអាវនឹងមានការប្រើប្រាស់ខុស ហើយ ផ្តល់ផលអាក្រក់ស្រដៀងគ្នានឹងថ្នាំញៀនក្នុងតារាង I រឺក្នុងតារាង II រឺកំប្រែទៅជាថ្នាំ ញៀនមួយវិញនោះ វាត្រូវប្រាប់អំពីការរកឃើញនោះដល់គណៈកម្មការដែលអាចសំរេចថា សារធាតុនោះត្រូវបញ្ចូលបន្ថែមទៅក្នុងតារាង I រឺក្នុងតារាង II ដោយអនុលោមទៅតាមអនុ សាសន៍របស់អង្គការសុខភាពពិភពលោក ។

៤- ប្រសិនបើអង្គការពិភពលោកដឹងថាមានការរៀបចំមួយ ដោយសារតែសារធាតុដែលទុកមិនអាច នឹង មានការប្រើប្រាស់ខុស ហើយមិនបង្កើតអោយមានឥទ្ធិពលអាក្រក់(កថាខ័ណ្ឌ៣)ហើយដឹងថាថ្នាំដែល មាននៅក្នុងនោះមិនអាចបំលែងបាននោះ គណៈកម្មការអាចបញ្ចូលការរៀបចំនោះបន្ថែមទៅក្នុងតា រាង III ដោយអនុលោមទៅតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក ។

៥- ប្រសិនបើអង្គការសុខភាពពិភពលោក ដឹងថាថ្នាំញៀនមួយក្នុងតារាង I អាចនឹងមានការប្រើប្រាស់ខុស ជាពិសេសនឹងអាចបង្កើតអោយមានឥទ្ធិពលអាក្រក់(កថាខ័ណ្ឌ៣) ហើយដឹងថាផលអាក្រក់បែបនោះ មិនអាចកើតចេញមកពីសារៈប្រយោជន៍ព្យាបាលរោគត្រឹមត្រូវ ដែលគ្មានក្នុងសារធាតុទាំងនោះក្រៅ ពីថ្នាំក្នុងតារាង៤ នោះគណៈកម្មការអាចដាក់ថ្នាំញៀននោះចូលក្នុងតារាង IV ។

៦- ទីកន្លែងណាមួយមានសេចក្តីប្រកាសជូនដំណឹងទាក់ទងនឹងថ្នាំញៀនមួយដែលមានជាស្រេច ក្នុងតារាង I រឺតារាង II រឺទាក់ទងនឹងការរៀបចំមួយក្នុងតារាង III ដាច់ចេញពីវិធានការដែលបានផ្តល់អោយ មានចែងនៅក្នុងកថាខ័ណ្ឌ៥នោះគណៈកម្មការអាចធ្វើវិសោធន៍កម្មតារាងណាមួយដោយអនុលោមទៅ តាមអនុសាសន៍របស់អង្គការសុខភាពពិភពលោកដោយៈ

ក- ផ្ទេរថ្នាំញៀនមួយពីតារាង I ទៅក្នុងតារាង II រឺពីតារាង II មកចូលតារាង I វិញ រឺ

ខ- លុបថ្នាំញៀនមួយរឺការរៀបចំមួយចេញពីតារាង I នៅពេលមានករណីបែបនេះ ។

៧- សេចក្តីសំរេចណាមួយរបស់គណៈកម្មការដែលបានធ្វើឡើងស្របទៅនឹងមាត្រានេះ អគ្គលេខាធិការត្រូវប្រកាសជូនដំណឹងដល់សមាជិករបស់អង្គការសហប្រជាជាតិ ភាគីរដ្ឋដែលមិនមែនជាសមាជិកអនុសញ្ញានេះ អង្គការសុខភាពពិភពលោកនិងដល់ក្រុមប្រឹក្សា។ សេចក្តីសំរេចបែបនេះត្រូវចូលជាធរមានចំពោះភាគីនីមួយៗ ចាប់ពីថ្ងៃទទួលដំណឹងរបស់ខ្លួន ហើយភាគីទាំងអស់នៅពេលនោះត្រូវចាត់វិធានការបែប ហ្នឹងនៅពេលណាគេតំរូវនៅក្នុងអនុសញ្ញានេះ ។

៨- ក- សេចក្តីសំរេចធ្វើវិសោធនកម្មទៅលើតារាងណាមួយរបស់គណៈកម្មការ ត្រូវតែពិនិត្យដោយហ្មត់ចត់ឡើងវិញដោយក្រុមប្រឹក្សាទៅលើសំណើរបស់ភាគីណាមួយ ដែលបានធ្វើប្រតិវេទក្នុងរយៈពេល ៩០ថ្ងៃចាប់ពីថ្ងៃទទួលសេចក្តីប្រកាសជូនដំណឹង ស្តីពីសេចក្តីសំរេចនោះ ។ សំណើអោយពិនិត្យឡើងវិញ ត្រូវបញ្ជូនទៅអោយអគ្គលេខាធិការព្រមគ្នាជាមួយពត៌មានពាក់ព័ន្ធ ដែលលើនោះ គេសំអាងទៅលើសំណើសុំអោយត្រួតពិនិត្យមើលយ៉ាងហ្មត់ចត់ឡើងវិញ ។

ខ- អគ្គលេខាធិការត្រូវបញ្ជូនច្បាប់ចំលង នៃសំណើសុំត្រួតពិនិត្យឡើងវិញ និង ពត៌មានដែលពាក់ព័ន្ធនោះ ទៅអោយគណៈកម្មការអង្គការសុខភាពពិភពលោក និង ទៅឱ្យភាគីទាំងអស់ដោយអញ្ជើញពួកគេអោយដាក់ជូននូវសេចក្តីអធិប្បាយមកក្នុងរយៈពេល ៩០ថ្ងៃ ។ សេចក្តីអធិប្បាយទាំងអស់ដែលបានទទួលត្រូវដាក់ជូនទៅក្រុមប្រឹក្សាដើម្បីពិនិត្យ ។

គ- ក្រុមប្រឹក្សាអាចអះអាងបញ្ជាក់កែតម្រូវឬប្តូរសេចក្តីសំរេចរបស់គណៈកម្មការនោះបញ្ច្រាសទៅវិញ ហើយសេចក្តីសំរេចរបស់ក្រុមប្រឹក្សាគឺជាសេចក្តីសំរេចចុងក្រោយ។ សេចក្តីប្រកាសជូនដំណឹងរបស់ក្រុមប្រឹក្សាត្រូវបញ្ជូនទៅឱ្យគ្រប់រដ្ឋទាំងអស់ ដែលជាសមាជិករបស់អង្គការសហប្រជាជាតិ ភាគីរដ្ឋដែលមិនមែនជាសមាជិកអនុសញ្ញានេះ គណៈកម្មការអង្គការសុខភាពពិភពលោក និង ទៅឱ្យក្រុមប្រឹក្សា ។

ឃ- ក្នុងកំឡុងពេលផ្អាកនៃការត្រួតពិនិត្យមើលឡើងវិញនោះ សេចក្តីសំរេចដើមរបសគណៈកម្មការត្រូវនៅមានប្រសិទ្ធិភាពដដែល។

៩- ដោយអនុលោមទៅតាមមាត្រានេះ សេចក្តីសំរេចរបស់គណៈកម្មការដែលបានធ្វើឡើងមិនត្រូវមាននីតិវិធីត្រួតពិនិត្យឡើងវិញដែលបានចែងក្នុងមាត្រា ៧ ។

## មាត្រា ៤

### កាតព្វកិច្ចទូទៅ

១- ភាគីទាំងអស់ត្រូវចាត់វិធានការផ្លូវច្បាប់ និង រដ្ឋបាលបែបនោះនៅពេលណាមានការចាំបាច់ៈ

ក- ដើម្បីផ្តល់ប្រសិទ្ធិភាព និង អនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ នៅក្នុងដែនដីរបស់ខ្លួន

ខ- ដើម្បីសហប្រតិបត្តិការជាមួយរដ្ឋដទៃទៀតក្នុងការប្រតិបត្តិបទបញ្ញត្តិនៃអនុសញ្ញានេះ ហើយ

គ- ត្រូវតែមានបទបញ្ញត្តិនៃអនុសញ្ញានេះ ដើម្បីកំរិតទាំងស្រុងចំពោះគោលបំណង ផ្នែកវិទ្យាសាស្ត្រ និង សុខាភិបាល ការដាំដុះ ការផលិត ការនាំចេញ ការនាំចូល ការចែកចាយ ការប្រើ និង កម្មសិទ្ធិថ្នាំញៀន ។

## មាត្រា ៥

### អង្គការត្រួតពិនិត្យអន្តរជាតិ

ភាគីទាំងអស់ដែលទទួលស្គាល់នូវសត្តកិច្ចរបស់អង្គការសហប្រជាជាតិ ចំពោះការត្រួតពិនិត្យថ្នាំញៀនអន្តរជាតិ យល់ព្រម មានជំនឿទុកចិត្តទៅគណៈកម្មការ ស្តីអំពី ថ្នាំញៀនរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម និង ទៅលើក្រុមប្រឹក្សាត្រួតពិនិត្យថ្នាំញៀនអន្តរជាតិ មុខងារដែលបានប្រគល់ជូនពួកគេរៀងៗខ្លួនទៅក្នុងអនុសញ្ញានេះ ។

## មាត្រា ៦

### ការចំណាយរបស់អង្គការត្រួតពិនិត្យអន្តរជាតិ

ការចំណាយរបស់គណៈកម្មការ និង ក្រុមប្រឹក្សាត្រូវផ្តល់អោយដោយអង្គការសហប្រជាជាតិ ក្នុងលក្ខណៈបែបនេះត្រូវសំរេចដោយមហាសន្និបាត ។ ភាគីទាំងអស់ដែលមិនមែនជាសមាជិករបស់អង្គការសហប្រជាជាតិត្រូវរួមវិភាគទានដល់ការចំណាយទាំងនេះនូវចំនួនដែលមហាសន្និបាទសយល់ថាសមស្របតាមពេល និង ការវាយតំលៃបន្ទាប់ពីការប្រឹក្សាជាមួយនឹងរដ្ឋាភិបាលរបស់ភាគីទាំងនេះ ។

## មាត្រា ៧

### ការត្រួតពិនិត្យសេចក្តីសំរេច និង អនុសាសន៍របស់គណៈកម្មការឡើងវិញ

លើកលែងតែសេចក្តីសំរេចនៅក្នុងមាត្រា ៣ សេចក្តីសំរេច ឬ អនុសាសន៍ នីមួយៗដែលបានអនុម័តដោយគណៈកម្មការ ដោយអនុលោមទៅ តាមបទបញ្ញត្តិនៃអនុសញ្ញានេះ ត្រូវតែមានការយល់ព្រម ឬ ការកែប្រែពីក្រុមប្រឹក្សាឬមហាសន្និបាតតាមវិធីដូចគ្នា នឹងការសំរេច ឬ អនុសាសន៍ របស់គណៈកម្មការដទៃៗទៀតដែរ ។

## មាត្រា ៨

## មុខងាររបស់គណៈកម្មការ

គណៈកម្មការត្រូវបានផ្តល់អាជ្ញាអោយ ដើម្បីយកបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងគោលបំណងរបស់អនុសញ្ញានេះមកពិនិត្យ ហើយជាពិសេស :

ក-ដើម្បីធ្វើវិសោធនកម្មតារាងទាំងឡាយដោយអនុលោមតាមមាត្រា ៣ ។

ខ-ដើម្បីជំរាបប្រាប់ក្រុមប្រឹក្សាអោយផ្តោតទៅលើបញ្ហាណាមួយ ដែលអាចទាក់ទងនឹងមុខងាររបស់ក្រុមប្រឹក្សានេះ ។

គ- ដើម្បីផ្តល់អនុសាសន៍ដល់ការអនុវត្តន៍ គោលបំណងនិងបទបញ្ញត្តិនៃអនុសញ្ញានេះ ដោយរាប់បញ្ចូលនូវកម្មវិធីស្រាវជ្រាវផ្នែកវិទ្យាសាស្ត្រ និង ការផ្លោះប្តូរពត៌មាននៃធម្មជាតិផ្នែកវិទ្យាសាស្ត្រ ឬ បច្ចេកទេស ហើយនិង

ឃ- ដើម្បីទាញអារម្មណ៍របស់ភាគីមិនមែនជារបស់ខ្លួន អោយយកចិត្តទុកដាក់ទៅលើការសំរេច និងអនុសាសន៍ទាំងឡាយដែលខ្លួនអនុម័តនៅក្នុងអនុសញ្ញានេះ ជាមួយនឹងការយល់ឃើញចំពោះ ការយកចិត្តទុកដាក់របស់ពួកគេ ដែលចាត់វិធានការឡើងដោយអនុលោមទៅតាមនោះ ។

## មាត្រា ៩

## សមាសភាពរបស់ក្រុមប្រឹក្សា

១- ក្រុមប្រឹក្សាត្រូវមានសមាជិក ១១រូប ដែលបោះឆ្នោតជ្រើសរើសឡើងដោយក្រុមប្រឹក្សា មានដូចតទៅ :

ក- សមាជិក ៣រូបដែលមានបទពិសោធន៍ ខាងវិជ្ជាពេទ្យ ឱសថវិទ្យា រឺ លក់ឱសថ ជ្រើសរើសចេញពីបេក្ខជន ៥រូបដែលអង្គការសុខភាពពិភពលោកជ្រើសរើសអោយឈរឈ្មោះនិង

ខ- សមាជិក ៨រូបទៀតជ្រើសចេញពីបញ្ជីឈ្មោះបេក្ខជនដែលជ្រើសរើសអោយឈរឈ្មោះដោយសមាជិកអង្គការសហប្រជាជាតិ និង ភាគីដែលមិនមែនជាសមាជិករបស់អង្គការសហប្រជាជាតិ ។

២- តាមរយៈសម្ពតកិច្ចភាគីមិនលំអៀង និង ភាពគ្មានផលប្រយោជន៍របស់ពួកគេ សមាជិកទាំងអស់របស់ក្រុមប្រឹក្សាគឺជាមនុស្សដែលមិនត្រូវអោយរក្សាការសម្ងាត់ទូទៅ ។ក្នុងអំឡុងរយៈពេលកាន់ដំណែងរបស់ខ្លួន ពួកគេមិនត្រូវមានតំណាងណាមួយ រឺ ចូលរួមក្នុងសកម្មភាព ណាមួយដែលអាចនិងបណ្ដាលអោយប៉ះពាល់ដល់ភាពមិនលំអៀងក្នុងការអនុវត្តមុខងាររបស់ខ្លួន ។ ក្រុមប្រឹក្សាត្រូវធ្វើការរៀបចំទាំងអស់ដែលចាំបាច់ដើម្បីធានាដល់ឯករាជ្យភាពរបស់ក្រុមប្រឹក្សា ។

៣- ដោយគោរពគោការណ៍នៃការតំណាងភូមិសាស្រ្ត ដែលមានសមធម៌ ក្រុមប្រឹក្សាត្រូវពិនិត្យពិចារណាទៅលើសារៈសំខាន់នៃការបញ្ចូលទៅក្នុងក្រុមប្រឹក្សា ក្នុងសមាមាត្រដែលមានសមធម៌ នូវមនុស្សដែលមានចំណេះដឹងពីស្ថានភាពថ្នាំញៀននៅក្នុងប្រទេសដែលដាំ ផលិតនិងប្រើប្រាស់ហើយដែលជាប់ទាក់ទងនឹងបណ្ដាប្រទេសទាំងនោះ ។

## មាត្រា១០

### រយៈពេលកាន់តំណែង និង សំណងរបស់សមាជិកក្រុមប្រឹក្សា

១- សមាជិកក្រុមប្រឹក្សាទាំងអស់ត្រូវបំរើការរយៈពេល៣ឆ្នាំហើយត្រូវមានសិទ្ធិទទួលបាននូវការបោះឆ្នោតជ្រើសរើសសាជាថ្មី ។

២- រយៈពេលកាន់តំណែងរបស់សមាជិកក្រុមប្រឹក្សាម្នាក់ៗ ត្រូវបញ្ចប់មួយថ្ងៃមុនពេលកិច្ចប្រជុំលើកទី ១ របស់ក្រុមប្រឹក្សា ដែលអ្នកថ្មីត្រូវមានសិទ្ធិចូលក្នុងកិច្ចប្រជុំនេះ ។

៣- សមាជិកក្រុមប្រឹក្សារូបណាមួយដែលមិនបានចូលរួមក្នុងសម័យប្រជុំបីជាប់ៗគ្នាត្រូវចាត់ទុកថាបានលាលែងពីការងារ ។

៤- ដោយផ្អែកលើអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល ក្រុមប្រឹក្សាអាចបណ្ដេញសមាជិកក្រុមប្រឹក្សាណាម្នាក់ដែលបានឈប់បំពេញល័ក្ខខ័ណ្ឌដែលតំរូវសំរាប់សមាជិកភាព ដែលមានចែងក្នុងកថាខ័ណ្ឌ២ នៃ មាត្រា៩ ។

៥- នៅពេលកន្លែងទំនេរកើតឡើងក្នុងក្រុមប្រឹក្សាភិបាលរយៈពេលកាន់តំណែងរបស់សមាជិកម្នាក់ ក្រុមប្រឹក្សាត្រូវបំពេញកន្លែងនោះភ្លាមតាមដែលអាចធ្វើទៅបាន ហើយដោយអនុលោមទៅតាមបទបញ្ញត្តិដែលអនុវត្តនៃមាត្រា៩ ដោយបោះឆ្នោតជ្រើសរើសសមាជិកម្នាក់ផ្សេងទៀត ដើម្បីអោយបំរើការរយៈពេលដែលនៅសល់ ។

៦- សមាជិករបស់ក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវទទួលសំណងគ្រប់គ្រាន់ដូចដែលបានកំណត់ដោយមហាសន្និបាត ។

## មាត្រា ១១
## ច្បាប់នីតិវិធីរបស់ក្រុមប្រឹក្សាភិបាល

១- គណៈកម្មការក្រុមប្រឹក្សាភិបាល ត្រូវបោះឆ្នោតរើសប្រធានផ្ទាល់របស់ខ្លួន និង មន្ត្រីដទៃទៀតនៅពេលណាខ្លួនគិតថា ចាំបាច់ ហើយត្រូវអនុមត័ច្បាប់នីតិវិធីរបស់ខ្លួន ។

២- គណៈកម្មការក្រុមប្រឹក្សាភិបាល ត្រូវជួបប្រជុំអោយបានញឹកញាប់ទៅតាមការយល់ឃើញរបស់ខ្លួននៅពេលណាចាំបាច់ ដើម្បីបំពេញមុខងាររបស់ខ្លួនអោយបានត្រឹមត្រូវ ប៉ុន្តែត្រូវយ៉ាងហោចណាស់ពីរសម័យប្រជុំក្នុងឆ្នាំប្រតិទិននីមួយៗ ។

៣- គោរពចាំបាច់ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាលត្រូវមានសមាជិក ៧រូប ។

## មាត្រា ១២
## ការគ្រប់គ្រងប្រព័ន្ធតំលៃប៉ាន់ស្មាន

១- ក្រុមប្រឹក្សាភិបាលត្រូវកំណត់កាលបរិច្ឆេតមួយឬច្រើន តាមរយៈនេះ និង បែបបទមួយដែលក្នុងនោះតំលៃប៉ាន់ស្មាន់ដូចដែលចែងក្នុងមាត្រា ១៩ ត្រូវផ្តល់ និង ត្រូវចេញទំរង់បែបបទដូច្នោះ ។

២- ដោយគោរពដែនដី និង ប្រទេសទាំងឡាយដែលមិនបានអនុវត្តអនុសញ្ញានេះ ក្រុមប្រឹក្សាភិបាលត្រូវស្នើដល់រាជរដ្ឋាភិបាលពាក់ព័ន្ធនូវតំលៃប៉ាន់ស្មានអនុលោមទៅតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ។

៣- ប្រសិនបើរដ្ឋណាខកខានមិនបានផ្ដល់តំលៃប៉ាន់ស្មាន ដោយគោរពដល់ដែនដីរបស់ខ្លួនតាមកាលបរិច្ឆេទដែលបានបញ្ជាក់នោះ ក្រុមប្រឹក្សាភិបាលត្រូវបង្កើតតំលៃប៉ាន់ស្មានអោយហួសតាមលទ្ធភាពដែលអាចធ្វើទៅបាន ។ ក្នុងការបង្កើតតំលៃប៉ាន់ស្មានបែបហ្នឹង អោយដល់កំរិតដែលអាចអនុវត្តបាន ក្រុមប្រឹក្សាភិបាលត្រូវធ្វើដូច្នេះ ក្នុងកិច្ចសហប្រតិបត្តិការជាមួយរាជរដ្ឋាភិបាលដែលពាក់ព័ន្ធ ។

៤- ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យមើលតំលៃប៉ាន់ស្មានដោយរាប់បញ្ចូលតំលៃប៉ាន់ស្មានបន្ថែមបង្គ្រប់ ហើយលើកលែងតំរូវការសំរាប់គោលបំណងពិសេសអាចតំរូវអោយមានពត៌មានបែបហ្នឹង នៅពេលណាខ្លួនគិតថាចាំបាច់ ដោយគោរពក្នុងនាមជាប្រទេស រឺ ទឹកដីមួយដែលគេផ្ដល់អោយនូវតំលៃប៉ាន់ស្មានមួយដើម្បី បំពេញតំលៃប៉ាន់ស្មាននោះ រឺ ដើម្បីពន្យល់លើសេចក្ដីអះអាងណាមួយដែលមាននៅក្នុងនោះ ។

៥- ក្រុមប្រឹក្សាភិបាលត្រូវអះអាចបញ្ជាក់លើតំលៃប៉ាន់ស្មានយ៉ាងរសរាន់តាម ដែលអាចធ្វើទៅបានដោយបញ្ចូលតំលៃប៉ាន់ស្មានបន្ថែមបង្គ្រប់ រឺ អាចធ្វើវិសោធនកម្មលើតំលៃប៉ាន់ស្មាននេះ ដោយមានការយល់ព្រមពីរដ្ឋាភិបាលពាក់ព័ន្ធ ។

៦- បន្ថែមលើរបាយការណ៍ដូចមានចែងក្នុងមាត្រា ១៥ ក្រុមប្រឹក្សាភិបាលត្រូវបញ្ចេញពត៌មានអំពីការប៉ាន់ប្រមាណទាំងនោះតាមយោបល់របស់ខ្លួន និង សំរបសំរួលការអនុវត្តអនុសញ្ញានេះនៅពេលដែលខ្លួនបានកំណត់យ៉ាងអោយណាស់មួយឆ្នាំម្ដង ។

## មាត្រា ១៣

## ការផ្ដល់ជូនប្រពន្ធ័ស្ថិតិបញ្ជូនត្រឡប

១. ក្រុមប្រឹក្សាត្រូវកំណត់ពីវិធីសាស្រ្ត និង បែបបទដែលត្រូវបញ្ជូនស្ថិតិត្រឡប់ដូចមានចែងក្នុងមាត្រា ២០ និង ត្រូវបញ្ជាក់អំពីវិធីសាស្រ្ត និង បែបបទទាំងនោះ ។

២. ក្រុមប្រឹក្សាភិបាលត្រូវពិនិត្យការបញ្ជូនត្រឡប់ជាមួយនឹងទស្សនៈនៃការកំណត់តើភាគីមួយ ឬ រដ្ឋផ្សេងទៀតណាមួយបានគោរពតាមបទបញ្ញត្តិនៃអនុសញ្ញានេះ ។

៣. ក្រុមប្រឹក្សាភិបាលអាចច្រូវការពត៌មាននោះបន្ថែមប្រសិនបើខ្លួនយល់ឃើញថាជាការចាំបាច់ក្នុងការ បញ្ចប់ ឬ ដើម្បីបកស្រាយពត៌មានដែលមាននៅក្នុងស្ថិតិបញ្ជូនត្រឡប់ទាំងនោះ ។

៤. មិនត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាលក្នុងការចោទសួរ ឬ បញ្ចេញគំនិតណាមួយ លើពត៌មានរបស់ស្ថិតិទាក់ទងនឹងគ្រឿងញៀនដែលតម្រូវចំពោះគោលបំណងពិសេសទាំងនេះ ។

## មាត្រា ១៤

## វិធានការរបស់ក្រុមប្រឹក្សាភិបាលដើម្បីធានាចំពោះការអនុវត្តន៍បញ្ញត្តិនៃអនុសញ្ញា

១. (ក) ដោយផ្អែកលើការត្រួតពិនិត្យរបស់ខ្លួនលើពត៌មានដែលរដ្ឋាភិបាលបានដាក់ជូនទៅក្រុមប្រឹក្សាភិបាល ស្របតាមបញ្ញត្តិនៃមាត្រានេះ ឬ តាមពត៌មានដែលអង្គការសហប្រជាជាតិបានជំរាបជូន និង ដែលមានសំណួរលិចឡើងពីបទបញ្ញត្តិទាំងនេះ ប្រសិនបើក្រុមប្រឹក្សាភិបាលមានហេតុផលជឿថា ដោយសារមូលហេតុ នៃការការខកខានរបស់ប្រទេសណាមួយ ឬ ដែនដីណាមួយក្នុងការអនុវត្តន៍ បញ្ញត្តិនៃមាត្រានេះក្រុមប្រឹក្សាត្រូវមានសិទ្ធិស្នើអោយមានការពន្យល់ពីពីរដ្ឋាភិបាលនៃប្រទេស ឬ ដែនដីដែលបានលើកឡើងនោះ ។ ដោយកំណត់ចំពោះសិទ្ធិរបស់ក្រុមប្រឹក្សាភិបាលក្នុងការបញ្ជាក់ ជូនដល់ភាគីនានា ក្រុមប្រឹក្សា និង គណកម្មការទទួលបន្ទុកលើបញ្ហាដូចដែលបានលើកឡើងក្នុង អនុកថាខណ្ឌ (គ) ខាងក្រោមខ្លួនត្រូវចាត់ទុកថាជាការសំងាត់ចំពោះសំណើររកពត៌មាន ឬ បក ស្រាយណាមួយរបស់រដ្ឋាភិបាលតាមអនុកថាខណ្ឌនេះ ។

(ខ) បន្ទាប់ពីការចាត់វិធានការតាមអនុកថាខណ្ឌ (ក) ខាងលើ ក្រុមប្រឹក្សាភិបាល ប្រសិនបើឯកភាព ថា វាជាការចាំបាច់ក្នុងការធ្វើដូច្នោះ អាចអំពាវនាវដល់រដ្ឋាភិបាលដែលពាក់ពន្ធ័អោយអនុម័ត វិធានការឧបាស្រ័យ ដូចដែលស្ថិតនៅក្រោមកាលៈទេសៈចាំបាច់ក្នុងការអនុវត្តន៍បទបញ្ញត្តិនៃ អនុសញ្ញា នេះ ។

(គ) ប្រសិនបើក្រុមប្រឹក្សាភិបាលរកឃើញថារដ្ឋាភិបាលដែលពាក់ពន្ធ័ខកខានក្នុងការផ្តល់ការពន្យល់ ណាមួយដែលអាចទទួលយកបាននៅពេលដែលមានការស្នើអោយធ្វើដូច្នោះតាមអនុកថាខណ្ឌ (ក) ខាងលើ ឬ ខកខានមិនបានអនុម័តវិធានការឧបាស្រ័យណាមួយដែលត្រូវបានគេស្នើអោយចាត់

វិធានការតាមអនុកថាខណ្ឌ (ខ) ខាងលើ ខ្លួនអាចស្នើអោយភាគីនានាយកចិត្តទុកដាក់ ក្រុមប្រឹក្សា និង គណៈកម្មការដែលទទួលបន្ទុកលើបញ្ហានេះ ។

២. នៅពេលស្នើអោយមានភាគីនានា ក្រុមប្រឹក្សា និង គណកម្មការដែលទទួលបន្ទុកលើបញ្ហានេះស្រប តាមកថាខណ្ឌ ១(គ) ខាងលើ ប្រសិនបើខ្លួនយល់ថាទង្វើបែបនេះជាការចាំបាច់ ក្រុមប្រឹក្សាភិបាល អាចផ្តល់ អនុសាសន៍ដល់ភាគីដោយអោយពួកគេបញ្ឈប់ការនាំចូលគ្រឿងញៀន ការនាំចេញគ្រឿង ញៀន ឬ ទង្វើទាំង ពីរ មកពី ឬ សំដៅទៅប្រទេស ឬ ដែនដីពាក់ព័ន្ធ ទោះបីក្នុងពេលវេលាមួយ កំណត់ ឬ រហូតដល់ក្រុមប្រឹក្សាភិបាលឯកភាពលើស្ថានភាពក្នុងប្រទេស ឬ ដែនដីនោះ ។ រដ្ឋពាក់ ព័ន្ធអាចលើកយកបញ្ហានេះដាក់ចំពោះមុខ ក្រុមប្រឹក្សា ។

៣. ក្រុមប្រឹក្សាភិបាលត្រូវមានសិទ្ធិបោះពុម្ពរបាយការណ៍ លើបញ្ហាណាមួយដែលបានដោះស្រាយដោយ អនុលោមទៅតាមបទបញ្ញត្តិនៃមាត្រានេះ ហើយបញ្ជូនរបាយការណ៍នេះទៅអោយក្រុមប្រឹក្សាដែល ត្រូវបញ្ជូនបន្តទៅអោយភាគីនានា ។ ប្រសិនបើក្រុមប្រឹក្សាភិបាលបោះពុម្ពផ្សាយក្នុងរបាយការណ៍ នេះនូវសេចក្តីសំរេចដែលបានធ្វើឡើងស្របតាមមាត្រានេះ ឬ ពត៌មានណាមួយដែលពាក់ព័ន្ធនឹង របាយការណ៍នេះ ខ្លួនក៏ត្រូវបោះពុម្ពផ្សាយនូវទស្សនៈរបស់រដ្ឋាភិបាលដែលពាក់ព័ន្ធផងដែរប្រសិនបើ មានការស្នើពីរដ្ឋាភិបាលទាំងនោះ ។

៤. ប្រសិនបើក្នុងករណីណាមួយដែលសេចក្តីសំរេចមួយរបស់ក្រុមប្រឹក្សាភិបាល ដែលបានបោះពុម្ពផ្សាយ ស្របតាមមាត្រានេះមិនមានការឯកភាពជាឯកឆន្ទ ត្រូវលើកបញ្ជាក់អំពីទស្សនៈរបស់មតិភាគតិច ។

៥. រដ្ឋណាមួយដែលត្រូវបានអញ្ជើញអោយចូលរួមក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ដែលសំណួរ មួយមានការចាប់អារម្មណ៍ដោយផ្ទាល់ ត្រូវបានពិចារណាតាមមាត្រានេះ ។

៦. សេចក្តីសំរេចរបស់ក្រុមប្រឹក្សាភិបាលតាមមាត្រានេះត្រូវធ្វើឡើងដោយមតិភាគច្រើនស្មើនឹងពីរភាគ បីនៃចំនួនក្រុមប្រឹក្សាភិបាលទាំងអស់ ។

## មាត្រា ១៥

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

១. ក្រុមប្រឹក្សាភិបាលត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំលើការងាររបស់ខ្លួន និង របាយការណ៍បន្ថែមនានាតាមដែលខ្លួនយល់ថាចាំបាច់ដែលត្រូវមានការវិភាគលើការចាំប្រមាណ និង ពត៌មានរបស់ស្ថិតិតាមសិទ្ធិ របស់ខ្លួន និង ក្នុងករណីសមស្របប្រវត្តិនៃការពន្យល់បកស្រាយប្រសិនបើមានដែលធ្វើឡើងដោយ ឬ ដោយសេចក្តីគំរូវរបស់រដ្ឋាភិបាលដោយរួមជាមួយទាំងការអង្កេតពិនិត្យនានា និងអនុសាសន៍ដែលក្រុមប្រឹក្សាភិបាលចង់ធ្វើ ។ របាយការណ៍ទាំងនេះត្រូវដាក់ជូនក្រុមប្រឹក្សាតាមរយៈគណកម្មការដែល អាចផ្តល់អន្តរាគមនានាតាមដែលខ្លួនឃើញថាសមស្រប ។

២. របាយការណ៍ត្រូវបញ្ជូនទៅអោយភាគីនិងបន្ទាប់មកត្រូវបោះពុម្ពផ្សព្វផ្សាយដោយអគ្គលេខាធិការ ។ ភាគីត្រូវអនុញ្ញាតអោយធ្វើការផ្សព្វផ្សាយបែងចែកដោយមិនមានការហាមប្រាមអ្វីទាំងអស់ ។

## មាត្រា ១៦

### អគ្គលេខាធិការដ្ឋាន

សេវាកម្មរបស់អគ្គលេខាធិការដ្ឋាននៃគណកម្មការ និង ក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអគ្គ-លេខាធិការ ។

## មាត្រា ១៧

### រដ្ឋបាលពិសេស

ភាគីត្រូវរក្សារដ្ឋាបាលពិសេសមួយដើម្បីគោលបំណងនៃការអនុវត្តន៍បទបញ្ញតិនៃអនុសញ្ញានេះ ។

## មាត្រា ១៨

### ពត៌មានដែលភាគីត្រូវផ្តល់ជូនទៅអគ្គលេខាធិការ

១. ភាគីត្រូវផ្តល់ជូនទៅអគ្គលេខានូវពត៌មានដូចនេះដូចដែលគណកម្មការអាចស្នើដោយសារជាការចាំបាច់ក្នុងការអនុវត្តន៍តួនាទីរបស់ខ្លួន និង ជាពិសេសៈ

(ក) របាយការណ៍ប្រចាំឆ្នាំស្តីអំពីដំណើរការរបស់អនុសញ្ញានៅក្នុងដែនដីនីមួយៗរបស់ពួកគេ

(ខ) ឯកសារច្បាប់ទាំងអស់ និង គោលការណ៍ពីពេលមួយទៅទៀតដែលបានប្រកាសអោយប្រើ ដើម្បីអោយអនុសញ្ញានេះចូលជាធរមាន

(គ) ករណីពិសេសៗទាំងនេះដែលតម្រូវអោយគណៈកម្មការត្រូវកំណត់ករណីដែលពាក់ពន្ធ័នឹងចរាចរខុសច្បាប់ ដោយរួមបញ្ចូលទាំងលក្ខណៈពិសេសលើករណីនីមួយៗនៃចរាចរខុសច្បាប់ដែលបានរក ឃើញថាអាចមានសារៈសំខាន់ ដោយសារមានពន្លឺលើប្រភពរបស់គ្រឿងញៀនដែលយកមកធ្វើចរាចរខុសច្បាប់ ឬ ដោយសារបរិមាណដែលពាក់ពន្ធ័ ឬ វិធីសាស្ត្រដែលអ្នកចរាចរខុសច្បាប់ប្រើប្រាស់ និង

(ឃ) ឈ្មោះ និង អាសយដ្ឋានរបស់អាជ្ញាធររដ្ឋាភិបាលដែលបានទទួលអំណាចក្នុងការចេញរបាយការណ៍ និង នាំចូលការអនុញ្ញាត ឬ វិញ្ញាបណ្ណបត្រ ។

២. ភាគីត្រូវផ្តល់ពត៌មានដូចមានយោងក្នុងកថាខណ្ឌខាងដើមតាមវិធី និង កាលបរិច្ឆេទព្រមទាំងប្រើប្រាស់បែបបទនោះដូចដែលគណៈកម្មការអាចស្នើ ។

## មាត្រា ១៩

### ការប៉ាន់ប្រមាណតម្រូវការថ្នាំ

១. ភាគីត្រូវផ្តល់ជូនដល់ក្រុមប្រឹក្សាភិបាលជារៀងរាល់ឆ្នាំនូវដែនដីនីមួយៗរបស់ខ្លួនតាមវិធី និង បែបបទ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល ការប៉ាន់ប្រមាណលើបែបបទដែលខ្លួនបានផ្តល់ជូនលើបញ្ហាដូច ខាងក្រោម

(ក) បរិមាណថ្នាំដែលត្រូវប្រើប្រាស់សំរាប់គោលបំណងផ្នែកវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ ។

(ខ) បរិមាណថ្នាំដែលត្រូវប្រើប្រាស់សំរាប់ការផលិតឱសថដ៏ទៃៗទៀត សំរាប់ការរៀបចំក្នុងតារាង III និងសារធាតុដែលមិនមានចែងក្នុងអនុសញ្ញានេះ ។

(គ) ស្តុកឱសថដែលត្រូវដាក់ដំកល់នៅថ្ងៃ ៣១ ខែ ធ្នូ នៃឆ្នាំដែលពាក់ពន្ធ័នឹងការធ្វើការប៉ាន់ប្រមាណ និង

(ឃ) បរិមាណឱសថដែលចាំបាច់សំរាប់បន្ថែមលើស្តុកពិសេសៗ ។

២. ដោយដាក់អោយធ្វើការកាត់បន្ថយដោយមានយោងក្នុងកថាខណ្ឌ ៣ នៃមាត្រា ២១ ការប៉ាន់ប្រមាណសរុបលើដែនដីនីមួយៗ និង ឱសថនីមួយៗត្រូវមានបរិមាណសរុបដូចដែលបានបញ្ជាក់ក្នុងអនុកថាខណ្ឌ (ក) (ខ) និង (គ) នៃកថាខណ្ឌ ១ នៃមាត្រានេះ ជាមួយនឹងការបន្ថែមរាល់បរិមាណដែលតម្រូវក្នុងការធ្វើអោយស្តុកជាក់ស្តែងមាននៅក្នុងដែនៅថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំមុនកើនដល់កំរិតដែលបានប៉ាន់ប្រមាណដូចមានចែងក្នុងអនុកថាខណ្ឌ (គ) នៃកថាខណ្ឌ ១ ។

៣. ក្នុងអំឡុងឆ្នាំ រដ្ឋណាមួយក៏អាចផ្តល់ការប៉ាន់ប្រមាណបន្ថែមជាមួយនឹងការពន្យល់បញ្ជាក់អំពីកាលៈទេសៈដែលតម្រូវអោយមានការប៉ាន់ប្រមាណបែបនោះ ។

៤. ភាគីត្រូវជូនពត៌មានដល់ក្រុមប្រឹក្សាភិបាល អំពីវិធីសាស្ត្រដែលបានប្រើប្រាស់ក្នុងការកំណត់ពីបរិមាណដែលបានបង្ហាញនៅក្នុងការប៉ាន់ប្រមាណ និង រាល់ការផ្លាស់ប្តូរនៅក្នុងវិធីសាស្ត្រនោះ ។

៥. ដោយដាក់កំរិតអោយមានការកាត់បន្ថយដូចមានយោងក្នុងកថាខណ្ឌ ៣ នៃ មាត្រា ២១ ការប៉ាន់ប្រមាណមិនត្រូវធ្វើអោយលើសនោះទេ ។

## មាត្រា ២០

## ស្ថិតិគ្រឡប់ដែលត្រូវផ្តល់ជូនទៅក្រុមប្រឹក្សាភិបាល

១. ភាគីត្រូវផ្តល់ជូនដល់ក្រុមប្រឹក្សាភិបាលចំពោះដែនដីនីមួយៗរបស់ខ្លួននូវស្ថិតិគ្រឡប់លើបែបបទដែលបានផ្តល់ជូនតាមវិធី និង បែបបទដែលបានកំណត់ ដោយក្រុមប្រឹក្សាភិបាលលើបញ្ហាដូចខាង ក្រោមៈ

(ក) ការផលិតគ្រឿងញៀន

(ខ) ការប្រើប្រាស់គ្រឿងញៀនដើម្បីផលិតថ្នាំផ្សេងៗទៀត ការរៀបចំក្នុងតារាង III និង សារធាតុគីមីដែលមានចែងក្នុងអនុសញ្ញានេះ និង ការប្រើប្រាស់ដើមរុក្ខជាតិញៀនសំរាប់ការផលិតថ្នាំញៀន

(គ) ការប្រើប្រាស់ថ្នាំញៀន

(ឃ) ការនាំចេញនាំចូលថ្នាំ និង រុក្ខជាតិញៀន

(ង) ការចាប់គ្រឿងញៀន និង ការបំផ្លាញចោល និង

(ច) ស្តុកគ្រឿងញៀននៅថ្ងៃ ៣១ ខែ ធ្នូនៃឆ្នាំដែលពាក់ពន្ធ័នឹងការបញ្ជូនគ្រឡប់ ។

២. (ក) ស្ថិតិត្រួតពិនិត្យទាក់ទងនឹងបញ្ហាដែលមានយោងក្នុងអនុកថាខណ្ឌ ១ លើកលែងតែ អនុកថាខណ្ឌ (ឃ) ត្រូវរៀបចំធ្វើជារៀងរាល់ឆ្នាំ និងត្រូវផ្តល់ជូនទៅអោយក្រុមប្រឹក្សាភិបាលមិនអោយលើសពីថ្ងៃទី ៣០ ខែ មិថុនា នៃឆ្នាំបន្ទាប់ដែលពាក់ព័ន្ធ ។

(ខ) ស្ថិតិត្រួតពិនិត្យទាក់ទងនឹងបញ្ហាដូចមានយោងក្នុងអនុកថាខណ្ឌ (ឃ) នៃកថាខណ្ឌ ១ ត្រូវធ្វើឡើង ៣ ខែម្តង និង ត្រូវបញ្ជូនទៅអោយក្រុមប្រឹក្សាភិបាលក្នុងអំឡុងពេល ១ ខែ បន្ទាប់ពីបញ្ចប់នៃរយៈពេល ៣ ខែដែលពាក់ព័ន្ធនោះ ។

៣. បន្ថែមលើបញ្ហាដែលមានយោងក្នុងកថាខណ្ឌ ១ នៃមាត្រានេះភាគីក៏អាចបញ្ជូនទៅអោយក្រុមប្រឹក្សាភិបាលអំពីដែនដីរបស់ខ្លួននីមួយៗនូវព័ត៌មានដែលទាក់ទងនឹងតំបន់ដែលបានប្រើប្រាស់ ដើម្បីដាំដុះសំរាប់ការផលិតអាភៀនតាមដែលអាចធ្វើទៅបាន (ជាហិចតា) ។

៤. ភាគីមិនត្រូវបានតំរូវអោយផ្តល់ស្ថិតិត្រួតពិនិត្យទាក់ទងនឹងការស្តុកពិសេសទេ ប៉ុន្តែត្រូវផ្តល់ការបញ្ជូនត្រួតពិនិត្យដាច់ដោយឡែកទាក់ទងនឹងថ្នាំញៀនដែលបាននាំចូល ឬ ដែលទទួលបាននៅក្នុងប្រទេស ឬ ដែនដីសំរាប់គោលបំណងពិសេសៗ ក៏ដូចជាបរិមាណគ្រឿងញៀនដែលបានដកចេញមកពីស្តុកពិសេសដើម្បីឆ្លើយតបនឹងសេចក្តីត្រូវការរបស់ប្រជាជនស៊ីវិល ។

## មាត្រា ២១
## ការដាក់កំរិតលើការផលិត និង ការនាំចូល

១. បរិមាណសរុបលើគ្រឿងញៀននីមួយៗដែលបានផលិត និង នាំចូលដោយប្រទេសណាមួយ ឬ ដែនដីណាមួយក្នុងឆ្នាំណាមួយមិនត្រូវលើសបរិមាណសរុបដូចខាងក្រោមៈ

(ក) បរិមាណដែលបានប្រើប្រាស់ នៅក្នុងកំរិតនៃការប៉ាន់ប្រមាណដែលពាក់ព័ន្ធសំរាប់ប្រើក្នុងគោលបំណងផ្នែកវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ

(ខ) បរិមាណដែលបានប្រើ នៅក្នុងកំរិតនៃការប៉ាន់ប្រមាណដែលពាក់ព័ន្ធចំពោះការផលិតឱសថផ្សេងៗទៀត សំរាប់ការរៀបចំធ្វើតារាង III និង សារធាតុគីមីដែលមិនមានចែងក្នុងអនុសញ្ញា

(គ) បរិមាណដែលបាននាំចេញៈ

(ឃ) បរិមាណដែលបានបន្ថែមលើស្តុក ដើម្បីធ្វើអោយស្តុកនោះស្មើនឹងកំរិតដែលបានកំណត់ក្នុងការប៉ាន់ប្រមាណដែលពាក់ព័ន្ធ និង

(ង) បរិមាណដែលទទួលបានក្នុងកំរិតនៃការប៉ាន់ប្រមាណដែលពាក់ព័ន្ធសំរាប់គោលបំណងពិសេស ។

២. ពីចំនួននៃបរិមាណដែលបានកំណត់ក្នុងកថាខណ្ឌ ១ ត្រូវធ្វើការកាត់បន្ថយនូវបរិមាណទាំងឡាយណាដែលបានរឹបអូស ឬ បានបញ្ចេញសំរាប់ការប្រើប្រាស់ស្របច្បាប់ ក៏ដូចជាបរិមាណដែលបានយកចេញមកពីស្តុកពិសេសសំរាប់បំរើសេចក្តីត្រូវការរបស់ប្រជាជនស៊ីវិល ។

៣. ប្រសិនបើក្រុមប្រឹក្សាភិបាលរកឃើញថាបរិមាណដែលបានផលិត និង នាំចូលក្នុងឆ្នាំណាមួយដែលលើសពីបរិមាណដែលបានកំណត់ក្នុងកថាខណ្ឌ ១ តិចជាងការកាត់បន្ថយណាមួយដូចដែលតម្រូវដោយកថាខណ្ឌ ២ នៃមាត្រានេះ ការលើសណាមួយដែលបានបង្កើតឡើង ឬ នៅសល់នៅចុងឆ្នាំត្រូវកាត់បន្ថយបរិមាណដែលត្រូវផលិត ឬ នាំចូល និង ពីចំនួននៃការប៉ាន់ប្រមាណសរុបនៅក្នុងឆ្នាំបន្ទាប់ដូចបានកំណត់និយមន័យក្នុងកថាខណ្ឌ ២ នៃមាត្រា ១៩ ។

៤. (ក) ប្រសិនបើក្នុងស្ថិតិត្រឡប់ស្តីអំពីការនាំចូល ឬ ការនាំចេញ (មាត្រា ២០) បង្ហាញថាបរិមាណដែលបាននាំចេញទៅប្រទេសណាមួយ ឬ ដែនដីណាមួយលើចំនួននៃការប៉ាន់ប្រមាណសរុបសំរាប់ប្រទេស នោះ ឬ ដែនដីនោះដូចបានកំណត់ក្នុងកថាខណ្ឌ ២ នៃមាត្រា ១៩ ជាមួយនឹងការបន្ថែមលើបរិមាណដែលបានបង្ហាញថានាំចេញ និងបន្ទាប់ពីការកាត់បន្ថយនូវចំនួនដែលលើសដូចមានកំណត់ក្នុងកថាខ័ណ្ឌ ៣ នៃមាត្រានេះក្រុមប្រឹក្សាភិបាលអាចជូនដំណឹងពីអង្គហេតុនេះទៅរដ្ឋដែលតាមយោបល់ របស់ក្រុមប្រឹក្សាភិបាលដែលសំរេចថាត្រូវជូនដំណឹងទាំងនោះ

(ខ) ក្រោយពីបានទទួលការជូនដំណឹង ភាគីមិនត្រូវផ្តល់សិទ្ធិអោយមានការនាំចេញគ្រឿងញៀនដែលពាក់ព័ន្ធនឹងប្រទេសនោះ ឬ ដែនដីនោះបន្ថែមទៀតទេក្នុងឆ្នាំនោះលើកលែងតែ :

(១) ក្នុងករណីនៃការប៉ាន់ប្រមាណបន្ថែមត្រូវបានធ្វើឡើងចំពោះប្រទេស ឬ ដែនដីនោះទាក់ទងនឹងបរិមាណដែលបាននាំចូលលើស និង បរិមាណបន្ថែមដែលតំរូវ ឬ

(២) ក្នុងករណីលើកលែងដែលការនាំចេញ គឺមានសារៈសំខាន់ក្នុងការព្យាបាលជំងឺទៅតាមយោបល់របស់រដ្ឋាភិបាលនៃប្រទេសនាំចេញ ។

## មាត្រា ២២

### បញ្ញត្តិពិសេសដែលអាចអនុវត្តបានចំពោះការដាំដុះ

នៅពេលដែលមានលក្ខខណ្ឌចាំបាច់ក្នុងប្រទេស ឬ ដែនដីមួយរបស់ភាគីហាមប្រាមដល់ការដាំដុះដើមអាភៀន ដើមកូកា ឬ ដើមកញ្ឆាដែលជាមធ្យោបាយមួយសមស្រប តាមគំនិតរបស់ខ្លួនដើម្បីការពារសុខភាព និង សុខមាលភាព និង ការបង្ការការបំលែងគ្រឿងឱសថអោយទៅជាគ្រឿងញៀនស្រវឹង ភាគីដែលពាក់ពន្ធ័ត្រូវធ្វើការហាមឃាត់ការធ្វើការដាំដុះនោះ ។

## មាត្រា ២៣

### ភ្នាក់ងារអាភៀនជាតិ

១. ភាគីមួយដែលអនុញ្ញាតអោយមានការដាំដុះដើមអាភៀន សំរាប់ការផលិតអាភៀនប្រសិនបើមិនទាន់មាននៅឡើយទេត្រូវបង្កើត និងរក្សាភ្នាក់ងាររដ្ឋាភិបាលមួយ ឬ ច្រើន (ដែលនៅផ្នែកខាងក្រោយនៃមាត្រានេះ ហៅកាត់ថាជាភ្នាក់ងារ) ដើម្បីអនុវត្តភារៈកិច្ចដែលតំរូវ ដោយមាត្រានេះ ។

២. ភាគីនីមួយៗត្រូវអនុវត្តបញ្ញតិខាងក្រោមចំពោះការដាំដុះដើមអាភៀន ការផលិតអាភៀន និង អាភៀនៈ

(ក) ភ្នាក់ងារត្រូវដាក់ទីតាំងដែលក្នុងទីតាំងនោះ និង ចំនែកដីនោះបានទទួលការអនុញ្ញាតអោយដាំដើមអាភៀនដើម្បីផលិតអាភៀន ។

(ខ) មានតែការដាំដុះដែលទទួលអាជ្ញាបណ្ណ័ពីភ្នាក់ងារនេះទេ ត្រូវបានអនុញ្ញាតអោយមានការពាក់ពន្ធ័នៅក្នុងការដាំដុះ ។

(គ) អាជ្ញាប័ណ្ណនីមួយៗត្រូវបញ្ជាក់អោយបានច្បាស់ពីទំហំដីដែលបានទទួលការអនុញ្ញាតអោយដាំដុះ ។

(ឃ) រាល់ការដាំដុះដើមអាភៀនទាំងអស់ត្រូវតំរូវអោយធ្វើការបញ្ជូនដើមអាភៀនទាំងអស់ទៅអោយភ្នាក់ងារ ។ ភ្នាក់ងារត្រូវទិញ និង យកជាកម្មសិទ្ធិលើដើមទាំងនោះអោយបានឆាប់បំផុតដោយមិនអោយលើសពីរយៈពេល ៤ ខែ ក្រោយពីការបញ្ចប់ការប្រមូលផល ។

(ង) ចំពោះអាភៀន ភ្នាក់ងារត្រូវមានសិទ្ធិផ្តាច់មុខក្នុងការនាំចូល នាំចេញ លក់ដុំ និង រក្សាទុកក្នុងស្តុកចំពោះអ្វីដែលនៅសល់ពីការកាន់កាប់របស់អ្នកផលិតអាភៀនអាល់កាលូអ៊ីដ អាភៀនប្រើក្នុងវេជ្ជសាស្ត្រ ឬ អាភៀនផ្សំ ។ ភាគីមិនចាំបាច់ពង្រីកសិទ្ធិផ្តាច់មុខនេះចំពោះអាភៀនប្រើក្នុងវេជ្ជសាស្ត្រ និង អាភៀនផ្សំនោះទេ ។

៣. តួនាទីរបស់រដ្ឋាភិបាលដូចមានយោងក្នុងកថាខ័ណ្ឌ ២ ត្រូវអនុវត្តដោយភ្នាក់ងាររបស់រដ្ឋាភិបាលមួយ ប្រសិនបើរដ្ឋធម្មនុញ្ញរបស់ភាគីដែលពាក់ព័ន្ធអនុញ្ញាតអោយធ្វើបែបនោះ ។

## មាត្រា ២៤

## ការដាក់កំរិតលើការផលិតអាភៀនសំរាប់ការធ្វើជំនួញអន្តរជាតិ

១. (ក) ប្រសិនបើភាគីណាមួយមានបំណងចាប់ផ្តើមការផលិតអាភៀន ឬ បង្កើនការផលិតអាភៀនដែលមានស្រាប់ ខ្លួនត្រូវពិចារណាលើសេចក្តីត្រូវការអាភៀនជារួមរបស់ពិភពលោកដោយស្រប តាមការប៉ាន់ប្រមាណដែលបានបោះពុម្ពផ្សព្វផ្សាយដោយក្រុមប្រឹក្សាភិបាល ដើម្បីអោយការផលិតអាភៀនរបស់ ភាគីនោះមិនធ្វើអោយមានផលិតផលអាភៀនលើសលុបនៅក្នុងពិភពលោក ។

(ខ) ភាគីមួយមិនត្រូវអនុញ្ញាតអោយមានការផលិតអាភៀន ឬ បង្កើនការផលិតអាភៀនដែលមានស្រាប់ទេប្រសិនបើយល់ឃើញថា ការផលិត ឬ ការបង្កើនការផលិតនៅក្នុងដែនដីរបស់ខ្លួនអាចបណ្តាលអោយមានការចរាចរអាភៀនខុសច្បាប់ ។

២. (ក) ដោយយោលទៅតាមកថាខណ្ឌ ១ ភាគីមិនបានផលិតអាភៀនសំរាប់នាំចេញដល់ថ្ងៃ ១ ខែ មករា ១៩៦១ មានបំណងនាំអាភៀនដែលខ្លួនផលិតចេញក្នុងបរិមាណមិនលើសពី ៥ តោនប្រចាំឆ្នាំ ខ្លួនត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាភិបាល ដោយធ្វើការបញ្ជាក់ជូនជាមួយនឹងការជូនដំណឹងនោះនូវពត៌មានដូចជា:

(១) ការត្រួតពិនិត្យជាចាំបាច់ដូចសេចក្តីតំរូវរបស់អនុសញ្ញានេះ ទាក់ទងនឹងអាភៀនដែលត្រូវផលិត និង នាំចេញ និង

(២) ឈ្មោះរបស់ប្រទេសមួយ ឬ ច្រើនដែលនឹងត្រូវទទួលអាភៀនដែលនាំចេញនោះ ហើយក្រុមប្រឹក្សាភិបាលអាចឯកភាពលើការជូនដំណឹងនោះ ឬ អាចស្នើដល់ភាគីថាភាគីនេះមិនត្រូវពាក់ព័ន្ធក្នុងការផលិតគ្រឿងញៀនដើម្បីនាំចេញនោះទេ ។

(ខ) ក្នុងករណីភាគីណាមួយក្រៅពីភាគីដែលមានយោងក្នុងកថាខណ្ឌ ៣ ផលិតអាភៀនដើម្បីនាំចេញក្នុងបរិមាណលើសពីប្រាំតោនក្នុងមួយឆ្នាំ ខ្លួនត្រូវជូនដំណឹងដល់ក្រុមប្រឹក្សាដោយមានការបញ្ជាក់ក្នុងការជូនដំណឹងនោះនូវពត៌មានដូចតទៅ:

(១) បរិមាណដែលបានប៉ាន់ប្រមាណថាត្រូវផលិតដើម្បីនាំចេញ

(២) ការត្រួតពិនិត្យអាភៀនដែលនៅសល់ ឬ អាភៀនដែលបានស្នើថានឹងផលិត

(៣) ឈ្មោះរបស់ប្រទេសមួយ ឬ ច្រើនដែលនឹងទទួលអាភៀនដែលត្រូវនាំចេញ ហើយក្រុមប្រឹក្សាអាចធ្វើការឯកភាពលើការជូនដំណឹងនោះ ឬ អាចស្នើថាភាគីនោះមិនត្រូវពាក់ព័ន្ធនឹងការផលិតអាភៀនដើម្បីនាំចេញនោះទេ ។

៣. ទោះបីជាមានបញ្ញត្តិនៃអនុកថាខណ្ឌ (ក) និង (ខ) នៃកថាខណ្ឌ ២ ភាគីមួយដែលបាននាំចេញអាភៀនដែលខ្លួនបានផលិតក្នុងអំឡុងពេល ១០ ឆ្នាំមុនភ្លាមមុនឆ្នាំ ១៩៦១ ប្រទេសនោះអាចបន្តនាំចេញអាភៀនដែលខ្លួនផលិត ។

៤. (ក) ភាគីមួយមិនត្រូវនាំអាភៀនចេញពីប្រទេស ឬ ដែនដីណាមួយទេលើកលែងតែអាភៀនត្រូវបានផលិតនៅ:

(១) ភាគីមួយដូចមានចែងក្នុងកថាខណ្ឌ ៣

(២) ភាគីដែលបានជូនដំណឹងដល់ក្រុមប្រឹក្សាភិបាលដូចមានចែងក្នុងអនុកថាខណ្ឌ (ក) នៃកថាខណ ២ ឬ

(៣) ភាគីដែលបានទទួលការឯកភាពពីក្រុមប្រឹក្សាដូចមានចែងក្នុងអនុកថាខណ្ឌ (ខ) នៃកថាខណ្ឌ ២ ។

(ខ) ទោះបីជាអនុកថាខណ្ឌ (ក) នៃកថាខណ្ឌនេះ ភាគីមួយអាចនាំចូលអាភៀនដែលបានផលិតក្នុងប្រទេសណាមួយដែលបានផលិត និង នាំអាភៀនចេញក្នុងអំឡុងពេល ១០ ឆ្នាំមុនថ្ងៃទី ១ ខែ មករា ១៩៦១ ប្រសិនបើប្រទេសនោះបានបង្កើតឡើង និងរក្សាប្រព័ន្ធត្រួតពិនិត្យថ្នាក់ជាតិមួយ ឬ ភ្នាក់ងារសំរាប់

បំរើលើគោលបំណងដែលមានចែងក្នុងមាត្រា ២៣ និង មានមធ្យោបាយប្រកបដោយប្រសិទ្ធិភាពក្នុងការធានា ថាអាភៀនដែលខ្លួនផលិតមិនត្រូវបំបែងចូលទៅជាការចរាចរខុសច្បាប់ទេ ។

៥. បញ្ញត្តិនៃមាត្រានេះមិនបង្ការភាគីណាមួយពីៈ

(ក) ការផលិតអាភៀនគ្រប់គ្រាន់សំរាប់បំរើសេចក្តីត្រូវការរបស់ខ្លួន ឬ

(ខ) ពីការនាំចេញអាភៀនដែលចាប់បានមកពីចរាចរខុសច្បាប់ ទៅភាគីមួយផ្សេងទៀតស្រប តាមសេចក្តីតំរូវរបស់អនុសញ្ញានេះ ។

## មាត្រា ២៥

## ការត្រួតពិនិត្យដើមអាភៀនស្ងួត

១. ភាគីមួយដែលអនុញ្ញាតអោយមានការដាំដុះដើមអាភៀនសំរាប់គោលបំណងក្រៅពីការផលិតអាភៀនត្រូវចាត់វិធានការចាំបាច់ដើម្បីធានាអោយបានថាៈ

(ក) មិនត្រូវផលិតអាភៀនចេញពីដើមអាភៀនទេ ហើយ

(ខ) ការផលិតឱសថចេញពីដើមអាភៀនស្ងួត ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យដោយសមស្របបំផុត ។

២. ភាគីនានាត្រូវប្រើប្រាស់ដើមអាភៀនស្ងួតតាមប្រព័ន្ធនៃអាជ្ញាបណ្ណ័នាំចូល និង ការអនុញ្ញាតនាំចេញដូចមានចែងក្នុងមាត្រា ៣១ ពីកថាខណ្ឌ ៤ ដល់ ១៥ ។

៣. ភាគីត្រូវផ្តល់ពត៌មានស្ថិតិអំពីការនាំចេញ និង ការនាំចូលដើមអាភៀនស្ងួតដូចសេចក្តីតំរូវលើគ្រឿងញៀនដែរតាមមាត្រា ២០ កថាខណ្ឌ ១ (ឃ) និង ២ (ខ) ។

## មាត្រា ២៦

## ដើមកូកា និង ស្លឹកកូកា

១. ប្រសិនបើភាគីមួយអនុញ្ញាតអោយមានការដាំដុះ ដើមកូកាភាគីនោះត្រូវប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យស្លឹកកូកាដូចមានចែងក្នុងមាត្រា ២៣ ទាក់ទងនឹងការត្រួតពិនិត្យដើមអាភៀន ក៏ប៉ុន្តែដោយគោរព

ទៅតាមកថាខណ្ឌ ២ (ឃ) នៃមាត្រានោះ សេចក្តីត្រូវដែលដាក់ទៅលើ ភ្នាក់ងារដែលមានយោង នៅទីនេះត្រូវតែយកជាកម្មសិទ្ធិដើមរុក្ខជាតិនោះអោយបានកាន់កាប់ តាមដែលអាចធ្វើទៅបាន បន្ទាប់ពីការបញ្ចប់ការប្រមូលផល ។

២. ភាគីត្រូវធ្វើអោយអស់លទ្ធភាពចំពោះការជីកឬសគល់នៃគុម្ពកូកាដែលដុះដោយយថាហេតុ។ ពួកគេត្រូវបំផ្លាញគុម្ពកូកាទាំងនោះចោលប្រសិនបើមានការដាំដុះខុសច្បាប់ ។

## មាត្រា ២៧
## បញ្ញត្តិបន្ថែមទាក់ទងនឹងស្លឹកកូកា

១. ភាគីអាចអនុញ្ញាតអោយប្រើប្រាស់ស្លឹកកូកាដើម្បីរៀបចំធ្វើជាភ្នាក់ងាររសជាតិ ដែលមិន ត្រូវមានសារធាតុអាល់កាលូអ៊ីដ និង តាមការចាំបាច់នៃការប្រើប្រាស់នីមួយៗ អាចអនុញ្ញាតការផលិត ការនាំចូល ការធ្វើជំនួញ និង កម្មសិទ្ធិលើស្លឹកទាំងនោះ ។

២. ភាគីត្រូវផ្តល់ការប៉ាន់ប្រមាណដាច់ដោយឡែកពីគ្នា (មាត្រា ១៥) និង ពតិមានលើស្ថិតិ (មាត្រា ២០) ទាក់ទងនឹងស្លឹកកូកាសំរាប់យកទៅផ្សំធ្វើជាភ្នាក់ងាររសជាតិ លើកលែងតែថាស្លឹកកូកាដូចគ្នាត្រូវយកទៅប្រើប្រាស់សំរាប់ការដកសារធាតុអាល់កាលូអ៊ីត និង ភ្នាក់ងាររសជាតិ និង មានការបកស្រាយពន្យល់ក្នុងការប៉ាន់ប្រមាណ និង ពតិមានស្ថិតិ ។

## មាត្រា ២៨
## ការត្រួតពិនិត្យលើកញ្ឆា

១. ប្រសិនបើភាគីមួយអនុញ្ញាតអោយមានការដាំដុះដើមកញ្ឆាសំរាប់ការផលិតកញ្ឆា ឬ ជ័រកញ្ឆា ភាគីនោះត្រូវប្រើប្រាស់ប្រពន្ធ័គ្រប់គ្រងដូចមានចែងក្នុងមាត្រា ២៣ ទាក់ទងនឹងការ ត្រួតពិនិត្យដើមអាភៀន ។

២. អនុសញ្ញានេះ មិនត្រូវប្រើប្រាស់ចំពោះការដាំដុះដើមកញ្ឆាផ្តាច់មុខបំរើគោលបំណងឧស្សាហ៍កម្ម (ដើម ឬ គ្រាប់) ឬ ការធ្វើពិសោធន៍ផ្នែកកសិកម្មទេ ។

៣. ភាគីត្រូវអនុម័តវិធានការទាំងនេះទៅតាមការចាំបាច់ដើម្បីបង្ការការប្រើប្រាស់ខុស និង ការចរាចរខុសច្បាប់នូវស្លឹករបស់ដើមកញ្ឆា ។

## មាត្រា ២៩
## ការផលិត

១. ភាគីត្រូវតំរូវថាការផលិតឱសថត្រូវស្ថិតនៅក្រោមអាជ្ញាបណ្ណ័លើកលែងតែការផលិត នោះធ្វើឡើងដោយសហគ្រាសរបស់រដ្ឋមួយឬ ច្រើន ។

២. ភាគីត្រូវ :

(ក) គ្រួតពិនិត្យមនុស្ស និង សហគ្រាសទាំងអស់ដែលកំពុងអនុវត្ត ឬ ពាក់ពន្ធ័ក្នុងការផលិតឱសថ

(ខ) គ្រួតពិនិត្យតាមអាជ្ញាបណ្ណ័ នូវទីតាំង និង ទីកន្លែងនានាដែលការផលិតឱសថអាចមានដំណើរការ និង

(គ) តំរូវអ្នកផលិតឱសថដែលមានអាជ្ញាបណ្ណ័ទទួលការអនុញ្ញាតតាមពេលដោយមានការបញ្ជាក់អំពីប្រភេទ និង បរិមាណឱសថដែលពួកគេមានសិទ្ធិផលិត ។ ទោះជាដូច្នោះក៏ដោយការអនុញ្ញាតតាមពេលមិនចាំបាច់ត្រូវការអោយមានការរៀបចំទេ ។

៣. ភាគីត្រូវបង្ការការសន្សំបានច្រើននៅក្នុងកម្មសិទ្ធិរបស់អ្នកផលិតនូវបរិមាណគ្រឿងញៀន ស្រវឹង និងដើមអាភៀនស្ងួតលើសពីអ្វីដែលបានតំរូវសំរាប់ដំណើរការជំនួញធម្មតាដោយ ពិចារណាសំខាន់លើលក្ខខណ្ឌទីផ្សារ ។

## មាត្រា ៣០
## ជំនួញ និង ការចែកចាយ

១. (ក) ភាគីត្រូវកំណត់ថាការធ្វើជំនួញ និង ការចែកចាយគ្រឿងញៀនត្រូវស្ថិតនៅក្រោមអាជ្ញាបណ្ណ័លើកលែងតែក្នុងករណីដែលការធ្វើជំនួញ ឬ ការចែកចាយនោះធ្វើឡើងដោយសហគ្រាសរដ្ឋមួយ ឬ ច្រើន ។

(ខ) ភាគីត្រូវ:

(១) ត្រួតពិនិត្យលើមនុស្ស និង សហគ្រាសទាំងអស់ដែលកំពុងអនុវត្ត ឬ ពាក់ពន្ធ័ក្នុងការធ្វើជំនួញ ឬ ការចែកចាយគ្រឿងញៀន ។

(២) ត្រួតពិនិត្យតាមអាជ្ញាបណ្ណ័នូវទីតាំង និង ទីកន្លែងដែលការធ្វើជំនួញ និង ការចែកចាយកំពុងមានសកម្មភាព ។ លក្ខខណ្ឌ័នៃការចេញអាជ្ញាបណ្ណ័មិនចាំបាច់ក្នុងការរៀបចំនោះទេ ។

(គ) បញ្ញតនៃអនុកថាខណ្ឌ (ក) និង (ខ)ដែលទាក់ទងនឹងការចេញអាជ្ញាបណ្ណ័មិនអនុវត្តចំពោះបុគ្គលដែលបានទទួលការអនុញ្ញាតពេញលេញក្នុងការអនុវត្ត និង នៅពេលកំពងទទួលបន្ទុកការព្យាបាល ឬ បច្ចេកវិជ្ជាឡើយ ។

២. ភាគីក៏ត្រូវ :

(ក) បង្កាការសន្សំការប្រមូលទុកក្នុងកម្មសិទ្ធិរបស់អ្នកជំនួញ អ្នកចែកចាយ សហគ្រាសរដ្ឋ ឬ បុគ្គលដែលបានទទួលសិទ្ធិពេញលេញដូចមានយោងខាងលើ នូវបរិមាណនៃគ្រឿងញៀន និង ដើមគ្រឿងញៀនសំងួតដែលលើសពីអ្វីដែលបានកំណត់ក្នុងការប្រតិបត្តិជំនួញធម្មតាដែលទាក់ទងចាំបាច់នឹងសេក្តីត្រូវការរបស់ទីផ្សារ និង

(ខ) (១) តំរូវអោយមានវេជ្ជបញ្ជាចំពោះការផ្គត់ផ្គង់ ឬ ការបញ្ចេញថ្នាំទៅអោយ បុគ្គល ។ សេចក្តីតំរូវនេះមិនត្រូវអនុវត្តចំពោះថ្នាំណាដែលបុគ្គលអាចទទួលបានប្រើប្រាស់ បញ្ចេញ ឬ យកទៅប្រើប្រាស់លើភារៈ កិច្ចព្យាបាលរបស់ពួកគេដែលមានសេចក្តីអនុញ្ញាតត្រឹមត្រូវ ហើយស្រប នឹងច្បាប់ និង

(២) ប្រសិនបើភាគីយល់ថាវិធានការទាំងនេះជាការចាំបាច់ ឬ សមស្រប តំរូវថា វេជ្ជបញ្ជាចំពោះថ្នាំក្នុងតារាង I ត្រូវសរសេរលើបែបបទផ្លូវការដែលត្រូវបោះពុម្ពចេញជាកូនសៀវភៅ ដោយអាជ្ញាធររដ្ឋាភិបាលមានសម្ថកិច្ច ឬ ដោយសមាគមជំនាញដែលបានទទួលសិទ្ធអនុញ្ញាត ។

(៣) ចង់បានថាភាគីនានាតំរូវថាត្រូវធ្វើជាលាយលាក់អក្សរក្នុងការផ្តល់ថ្នាំ ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីអត្ថបទគ្រប់ប្រភេទ ឬ ការអត្ថាធិប្បាយដែលទាក់ទងនឹងថ្នាំ និង បានយកទៅប្រើក្នុងគោលបំណងពាណិជ្ជកម្ម ការរុំនៅខាងក្នុងកញ្ចប់ដែលមានថ្នាំ និង ផ្លាកយីហោ

ដែលគ្រឿងញៀននោះនឹងត្រូវលក់ បញ្ជាក់អំពីឈ្មោះគ្មានម្ចាស់កម្មសិទ្ធិអន្តរជាតិដែលផ្សព្វផ្សាយឡើងដោយអង្គការសុខភាពពិភពលោក ។

(៤) ប្រសិនបើភាគីមួយចាត់ទុកថាវិធានការនេះមានការចាំបាច់ ឬ ចង់បានវិធាន ការនេះខ្លួនត្រូវតំរូវថាផ្នែកខាងក្នុងកញ្ចប់ដែលមានថ្នាំ ឬសំបករុំត្រូវមានខ្សែពណ៌ក្រហមពីរច្បាស់ដែលអាចមើលឃើញ ។ ការរុំកញ្ចប់ផ្នែកខាងក្រៅដែលនៅក្នុងនោះមានថ្នាំមិនត្រូវមានខ្សែពណ៌ក្រហមទេ ។

(៥) ភាគីមួយត្រូវតំរូវថាផ្លាកសញ្ញាដែលដាក់លក់ថ្នាំត្រូវបង្ហាញពីប្រភេទថ្នាំជា ទម្ងន់ ឬជាភាគរយ ។ សេចក្តីតំរូវពិតិមានលើផ្លាកសញ្ញានេះមិនត្រូវអនុវត្តចំពោះថ្នាំដែលបានបញ្ចេញទៅអោយបុគ្គលតាមរយៈវេជ្ជបញ្ជានោះទេ ។

(៦) បញ្ញត្តិនៃកថាខណ្ឌ ២ និង ៥ មិនត្រូវអនុវត្តចំពោះការលក់រាយ ឬ ការចែកចាយរាយនៅគ្រឿងញៀនក្នុងតារាង ២ ទេ ។

## មាត្រា ៣១

## បញ្ញត្តិពិសេសទាក់ទងនឹងជំនួញអន្តរជាតិ

១. ភាគីមិនត្រូវអនុញ្ញាតអោយមានការនាំចេញគ្រឿងញៀនទៅប្រទេស ឬ ដែនដីណាមួយនោះទេ ប្រសិនបើខ្លួនដឹងលើកលែងតែ :

(ក) យោងទៅតាមច្បាប់ និង គោលការណ៍ដែលប្រទេស ឬ ដែនដីនោះ និង

(ខ) ក្នុងកំរិតចំនួនសរុបក្នុងការប៉ាន់ប្រមាណចំពោះប្រទេសនោះ ឬ ដែនដីនោះដូចបានកំណត់ក្នុងកថាខណ្ឌ ២ នៃមាត្រា ១៩ ជាមួយនឹងការបូកបន្ថែមលើចំនួនដែលគ្រោងថានឹងនាំចេញ ។

២. ភាគីត្រូវអនុវត្តក្នុងតំបន់ផែ និង តំបន់សេរីនូវបញ្ញត្តិដូចគ្នា និង ការត្រួតពិនិត្យដូចនៅក្នុងផ្នែកផ្សេងៗទៀតនៃដែនដីរបស់ពួកគេ ប្រសិនបើក្នុងករណីថាពួកគេអាចប្រើប្រាស់វិធានការខ្លាំងក្លាបន្ថែមទៀត ។

៣. ភាគីត្រូវ :

(ក) ត្រួតពិនិត្យតាមអាជ្ញាបណ្ណ័នាំចេញ និង នាំចូលគ្រឿងញៀនលើកលែងតែក្នុងករ ណីការនាំចេញ ឬ នាំចូលធ្វើឡើងដោយសហគ្រាសរបស់រដ្ឋ ។

(ខ) ត្រួតពិនិត្យមនុស្ស និង សហគ្រាសទាំងអស់ដែលកំពុងអនុវត្ត ឬ ជាប់ពាក់ពន្ធ័ក្នុងការនាំចេញ ឬ នាំចូល ។

៤. (ក) ភាគីនីមួយៗដែលអនុញ្ញាតអោយមានការនាំចេញ ឬ នាំចូលគ្រឿងញៀនត្រូវតំរូវអោយមានការផ្តល់សិទ្ធិអនុញ្ញាតអោយនាំចេញ ឬ នាំចូលដាច់ដោយឡែកមួយដែលត្រូវទទួលការអនុញ្ញាតនាំចេញ ឬ នាំចូលទាំងនោះទោះបីជាមានគ្រឿងញៀនមួយមុខ ឬ ច្រើនមុខក៏ដោយ ។

(ខ) ការអនុញ្ញាតនេះត្រូវបញ្ជាក់ពីឈ្មោះគ្រឿងញៀន ឈ្មោះដែលមិនមែនជាយីហោជំនួញអន្តរជាតិប្រសិនបើមាន បរិមាណដែលនឹងត្រូវនាំចូល ឬ នាំចេញ និង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកនាំចេញ និង នាំចូល និង ត្រូវកំណត់ពីរយៈពេលដែលការនាំចេញ ឬ ការនាំចូលនោះអាចប្រព្រឹត្តឡើង ។

(គ) សិទ្ធិអនុញ្ញាតនាំចេញក៏ត្រូវបញ្ជាក់ផងដែរពីចំនួន និង ការបរិច្ឆេតនៃបណ្ណ័នាំចូល (កថាខណ្ឌ ៥) និង អ្នកដែលចេញសិទ្ធិអនុញ្ញាតនោះ ។

(ឃ) សិទ្ធិអនុញ្ញាតនៃការនាំចូលអាចអនុញ្ញាតអោយមានការនាំចូលមួយធ្វើឡើង ច្រើនជាងមួយដង ។

៥. មុនការចេញសិទ្ធិអោយនាំចេញភាគីត្រូវតំរូវអោយមានបណ្ណ័អនុញ្ញាតអោយនាំចូលដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសដែលនាំចូល ឬ ដែនដី ហើយត្រូវកំណត់ថា ការនាំគ្រឿងញៀនចូលដូចមានចែងនេះត្រូវបានទទួលការឯកភាព ហើយបណ្ណ័ទាំងនោះ ត្រូវរៀបចំធ្វើឡើងដោយជននោះ ឬ ទីតាំងដែលបានដាក់ពាក្យសុំសិទ្ធិធ្វើការនាំចូល ។ ភាគីត្រូវធ្វើការតាមដានអោយបានយ៉ាងជិតដល់នូវបែបបទនៃបណ្ណ័នាំចូលដែលគណៈកម្ម ការបានឯកភាព ។

៦. ឯកសារចម្លងមួយច្បាប់នៃការអនុញ្ញាតអោយនាំចេញត្រូវដាក់អម តាមការផ្ញើបញ្ជូនរបស់រាល់លើក ហើយរដ្ឋាភិបាលដែលចេញសិទ្ធិអនុញ្ញាតអោយនាំចេញនោះត្រូវបញ្ជូនឯកសារ ចម្លងមួយច្បាប់ទៅអោយប្រទេស ឬ ដែនដីដែលត្រូវនាំចូល ។

៧. (ក) រដ្ឋាភិបាល និង ដែនដីដែលនាំចូល នៅពេលដែលការនាំចូលមានប្រសិទ្ធិភាព ឬ នៅពេលដែលរយៈពេលកំណត់នៃការនាំចូលត្រូវបានបញ្ចប់ ត្រូវបញ្ជូនត្រឡប់សិទ្ធិអនុញ្ញាតអោយនាំចេញជាមួយនឹងការបញ្ជាក់របស់ខ្លួនទៅអោយរដ្ឋាភិបាលនៃប្រទេសឬ ដែនដីដែលបាននាំចេញ ។

(ខ) សេចក្តីបញ្ជាក់ត្រូវកំណត់ពីបរិមាណដែលបាននាំចូល ។

(គ) ប្រសិនបើមានបរិមាណតិចជាងអ្វីដែលមានកំណត់ក្នុងសិទ្ធិអនុញ្ញាតនាំចេញ ត្រូវបាននាំចេញបរិមាណដែលបាននាំចេញនោះត្រូវបញ្ជាក់អោយបានច្បាស់លាស់ដោយអាជ្ញាធរមានសម ត្ថកិច្ចលើសិទ្ធិអនុញ្ញាតនាំចេញ និង លើឯកសារផ្លូវការផ្សេងៗទៀត ។

៨. ការបញ្ជូននាំចេញទៅប្រអប់សំបុត្រប្រៃយណីយ៍ ឬ ធនាគារដែលមានគណនីរបស់ភាគីមួយ ក្រៅពីភាគីដែលបានដាក់ឈ្មោះក្នុងសិទ្ធិអនុញ្ញាតអោយនាំចេញត្រូវបានហាមឃាត់ ។

៩. ការនាំចេញអ៊ីវ៉ាន់ទៅដាក់ក្នុងទីតាំងផ្ទុកទំនិញជួលត្រូវបានហាមឃាត់ លើកលែងតែរដ្ឋាភិបាលរបស់ប្រទេសដែលនាំចូលបញ្ជាក់លើបណ្ណ័នាំចូលដែលធ្វើឡើងដោយបុគ្គល ឬ ទីតាំងដែលបានដាក់ពាក្យសុំសិទ្ធនាំចេញដែលខ្លួនបានឯកភាពអោយមានការនាំចូលដោយមានបំណងថាដាក់ ក្នុងទីតាំងផ្ទុកទំនិញជួលនោះ ។ ក្នុងករណីនេះសិទ្ធិអនុញ្ញាតនៃការនាំចេញត្រូវកំណត់ថាឥវ៉ាន់ ទាំនោះត្រូវនាំចេញសំរាប់គោលបំណងនេះ ។ ការដកអ៊ីវ៉ាន់ណាមួយចេញពីទីតាំងនេះ ត្រូវធ្វើឡើងដោយមានការអនុញ្ញាតពីអាជ្ញាធរដែលមានដែនអំណាចលើទីតាំងផ្ទុកទំនិញនោះ និង ក្នុងករណីការបញ្ចេញទៅគោលដៅបរទេស ត្រូវចាត់ទុកថាជាការនាំចេញថ្មីមួយក្នុងអត្ថន័យនៃអនុ សញ្ញានេះ ។

១០. អ៊ីវ៉ាន់ជាគ្រឿងញៀនដែលចូល ឬ ចេញពីដែនដីរបស់ភាគីមួយដែលមិនមានអមដោយសិទ្ធិអនុញ្ញាតនាំចេញត្រូវដាក់ក្នុងការឃុំឃាំងដោយអាជ្ញាធរមានសមត្ថកិច្ច ។

១១. ភាគីមួយមិនត្រូវអនុញ្ញាតអោយផ្ញើបញ្ជូនគ្រឿងញៀនទៅប្រទេសមួយផ្សេងទៀតដោយ ឆ្លងកាត់ដែនដីរបស់ខ្លួនទោះបីជាទំនិញទាំងនោះ ត្រូវបានយកចេញពីមធ្យោបាយដឹកជញ្ជូនដែលកំពុងអនុវត្តលើកលែងតែមានឯកសារចម្លងមួយច្បាប់នៃសិទ្ធិអនុញ្ញាតអោយនាំចេញនូវទំនិញទាំងនេះ ដែលធ្វើឡើងដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ភាគីនេះ ។

១២. អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេស ឬ ដែនដីណាមួយដែលតាមរយៈនោះទំនិញជាគ្រឿងញៀនត្រូវបានអនុញ្ញាតអោយឆ្លងកាត់ត្រូវចាត់វិធានការសមស្រប ដើម្បីបង្ការការបែកខ្វែកទំនិញទៅគោលដៅណាមួយក្រៅពីគោលដៅដែលបានកំណត់ក្នុងឯកសារអមលើសិទ្ធិអនុញ្ញាតនាំ ចេញ លើកលែងតែរដ្ឋាភិបាលរបស់រដ្ឋ ឬ ដែនដីដែលមានទំនិញនោះឆ្លងកាត់ អនុញ្ញាតអោយ មានការដាក់ក្នុងទិសដៅផ្សេង ។ រដ្ឋាភិបាលនៃប្រទេស ឬ ដែនដីឆ្លងកាត់ត្រូវចាត់ទុកការបង្វែរ ទៅទិសដៅផ្សេងដូចជាការនាំចេញតាមប្រទេស ឬ ដែនដីឆ្លងកាត់ទៅប្រទេស ឬ ដែនដីផ្សេង ទៀតដែលជាគោលដីថ្មី ។ ប្រសិនបើការបង្វែរទិសដៅត្រូវបានទទួលការអនុញ្ញាតនៃក ថាខណ្ឌ ៧(ក) និង (ខ)ក៏ត្រូវអនុវត្តរវាងប្រទេស ឬ ដែនដីដែលឆ្លងកាត់ និង ប្រទេស ឬ ដែនដីដែលជាចំនុចចាប់ផ្តើមនៃការបញ្ជូនអ៊ីវ៉ាន់ ។

១៣. អ៊ីវ៉ាន់ជាគ្រឿងញៀននៅពេលឆ្លងកាត់ ឬ នៅពេលកំពុងដាក់ដិកល់ក្នុងឃ្លាំងមិនត្រូវស្ថិតនៅក្រោមដំណើរការណាមួយដែលអាចផ្លាស់ប្តូរធម្មជាតិនៃគ្រឿងញៀននោះទេ ។ កញ្ចប់រុំត្រូវរក្សាទុកនៅដដែលដោយមិនមានការកែប្រែប្រសិនបើមិនមានការអនុញ្ញាតពីអាជ្ញាធរមាន សមត្ថកិច្ច ។

១៤. បញ្ញត្តិនៃកថាខណ្ឌ ១១ ដល់ ១៣ ដែលទាក់ទងនឹងច្រកផ្លូវគ្រឿងញៀនតាមរយៈដែនដីរបស់ភាគីមួយមិនត្រូវអនុវត្តចំពោះទំនិញដូចបានលើកឡើងដែលដឹកជញ្ជូនដោយយន្តហោះ ហើយមិនចុះចតក្នុងប្រទេស ឬ ដែនដីឆ្លងកាត់នោះ ។ ប្រសិនបើយន្តហោះចុះចតក្នុងប្រទេស ឬ ដែនដីណាមួយ បពាតិទាំងនោះត្រូវយកទៅអនុវត្តទៅតាមកាលៈទេសៈត្រូវ ។

១៥. បញ្ញាតិនៃមាត្រានេះមិនរើសអើងចំពោះបញ្ញាតិដទៃៗទៀតរបស់កិច្ចព្រមព្រៀងអន្តរជាតិ ដែលកើតពីការត្រួតពិនិត្យដែលអាចអនុវត្តបានដោយភាគីណាមួយចំពោះគ្រឿងញៀនដែលកំពុងឆ្លងកាត់ ។

១៦. មិនមានអ្វីក្នុងមាត្រានេះក្រៅពីកថាខណ្ឌ ១(ក) និង ២ ត្រូវយកទៅអនុវត្តក្នុងករណីនៃការរៀបចំតារាង III ឡើយ ។

## មាត្រា ៣២

## បញ្ញត្តិពិសេសទាក់ទងនឹងការផ្ទុកគ្រឿងញៀនក្នុងប្រអប់ឧបករណ៍សង្គ្រោះបន្ទាន់របស់កប៉ាល់ ឬ យន្តហោះដែលពាក់ពន្ធ័នឹងការធ្វើចរាចរជាអន្តរជាតិ

១. ការដឹកជញ្ជូនជាអន្តរជាតិដោយកប៉ាល់ ឬ ដោយយន្តហោះនូវចំនួនគ្រឿងញៀនមួយដែលបានកំណត់តាមសេចក្តីត្រូវការជួយសង្គ្រោះបន្ទាន់នៅពេលធ្វើដំណើរ ឬ ករណីសង្គ្រោះបន្ទាន់មិនត្រូវចាត់ទុកថាជាការនាំចូលការនាំចេញ ឬ ឆ្លងកាត់តាមប្រទេសក្នុងអត្ថន័យ នៃអនុសញ្ញានេះទេ ។

២. ប្រទេសដែលបានចុះបញ្ជីត្រូវចាត់វិធានការសមស្រប ដើម្បីបង្ការការប្រើប្រាស់គ្រឿងញៀនមិនសមរម្យមានយោងក្នុងកថាខណ្ឌ ១ ឬ ការបង្វែរខុសទិសដៅសំរាប់ការចរាចរគ្រឿងញៀនខុសច្បាប់ ។ គណៈកម្មការ ដោយធ្វើការប្រឹក្សាជាមួយនឹងអង្គការអន្តរជាតិសមស្រប ត្រូវផ្តល់អនុសាសន៍ចំពោះការការពារទាំងនោះ ។

៣. គ្រឿងញៀនដែលដឹកជញ្ជូនដោយកប៉ាល់ ឬ យន្តហោះស្របតាមកថាខណ្ឌ ១ ត្រូវធ្វើឡើង ដោយស្របនឹងច្បាប់ គោលការណ៍ សេចក្តីអនុញ្ញាត និង អាជ្ញាបណ្ណ័របស់ប្រទេសដែលបានចុះបញ្ជី ដោយមិនរើសអើងចំពោះសិទ្ធិណាមួយរបស់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុងតំ បន់ក្នុងការអនុវត្តការឆែក ពិនិត្យ អធិការកិច្ច និង វិធានការត្រួតពិនិត្យផ្សេងៗទៀតលើ កប៉ាល់ ឬ លើយន្តហោះ ។ ការប្រើប្រាស់គ្រឿងញៀននៅក្នុងករណីសង្គ្រោះបន្ទាន់មិនត្រូវ ចាត់ទុកថាជាការរំលោភលើសេចក្តីតំរូវនៃមាត្រា ៣០ កថាខណ្ឌ ២(ខ) ។

## មាត្រា៣៣

## ការមានកម្មសិទ្ធិថ្នាំញៀន

ភាគីទាំងអស់មិនត្រូវអនុញ្ញាតអោយមានថ្នាំញៀនជាកម្មសិទ្ធិផ្ទាល់ខ្លួនទេ លើកលែងតែឋិតក្រោមអំណាចច្បាប់ ។

## មាត្រា៣៤

## ការត្រួតពិនិត្យមើលនិងអធិការកិច្ច

ភាគីទាំងអស់ត្រូវតំរូវអោយ :

ក- ជនទាំងឡាយដែលមានអាជ្ញាប័ណ្ណ ដូចដែលបានផ្តល់ជូន ដោយអនុលោមទៅតាមអនុសញ្ញានេះ រឺ ដែល មានតួនាទីត្រួតត្រាមើល រឺ គ្រប់គ្រងក្នុងសហគ្រាសរបស់រដ្ឋដែលបានបង្កើតឡើងដោយ

អនុលោមទៅតាមអនុសញ្ញានេះ ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដើម្បីប្រតិបត្តិបទបញ្ញត្តិច្បាប់ និង បទបញ្ញត្តិទាំងនោះ អោយមានប្រសិទ្ធភាពនិងប្រកបដោយភក្តីដូចដែលបានអនុម័តដោយអនុលោមទៅតាម នោះហើយ ។

ខ- អាជ្ញាធររដ្ឋាភិបាល អ្នកផលិត អ្នកជំនួញ អ្នកវិទ្យាសាស្ត្រ គ្រឹះស្ថានវិទ្យាសាស្ត្រ និង មន្ទីរពេទ្យ រក្សាទុករបាយការណ៍ដែលបានបង្ហាញពីថ្នាំញៀននិមួយៗ បានផលិត និង បរិមាណថ្នាំញៀនដែលទទួលបាន មួយមុខៗ ព្រមទាំងកាកសំណល់របស់ថ្នាំញៀន ។ បរិមាណទាំងនោះត្រូវរក្សាទុករៀងៗខ្លួន មិនអោយហួស រយៈពេល២ឆ្នាំឡើយ ។ គេប្រើសៀវភៅកត់ត្រាបញ្ញត្តិជាផ្លូវការ (មាត្រា ៣០ កថាខ័ណ្ឌ ២ (ខ)) សៀវភៅទាំងនោះ ចាប់បញ្ចូលទាំងគល់បញ្ជី ត្រូវរក្សាទុកផងដែរមិនអោយលើសរយៈពេល ២ឆ្នាំ ។

## មាត្រា៣៥

### សកម្មភាពប្រឆាំងនិងការជួញខុសច្បាប

ដោយមានការគោរពចំពោះប្រព័ន្ធរដ្ឋបាលច្បាប់ និង រដ្ឋធម្មនុញ្ញភាគីទាំងអស់ត្រូវ :

ក- រៀបចំកិច្ចសំរបសំរួលថ្នាក់ជាតិមួយ ដើម្បីសហប្រតិបត្តិការ សកម្មភាពការពារ និងបង្ក្រាប ប្រឆាំងនឹងការជួញខុសច្បាប់ដើម្បីឈានទៅដល់ការបញ្ចប់នេះ ពួកគេអាចជ្រើសភ្នាក់ងារសមស្របមួយ ដ៏មានសារៈប្រ យោជន៍អោយទទួលខុសត្រូវចំពោះកិច្ចសហប្រតិបត្តិការនោះ ។

ខ- ជួយគ្នាទៅវិញទៅមកក្នុងយុទនាការប្រឆាំង នឹង ការជួញថ្នាំញៀនខុសច្បាប់

គ- សហការយ៉ាងជិតស្និតជាមួយគ្នាទៅវិញទៅមក និង ជាមួយអង្គការអន្តរជាតិដែលមានសម្ថកិច្ច ដែលជា សមាជិកដោយមានគោលបំណងថែរក្សានូវយុទ្ធនាការសំរបសំរួលប្រឆាំង នឹង ការជួញខុសច្បាប់ ។

ឃ- ធានាថាកិច្ចសហប្រតិបត្តិការអន្តរជាតិ រវាងភ្នាក់ងារសំរបសំរួលត្រូវធ្វើឡើងដោយរូសរាន់ ហើយ

ង- ធានាដល់កន្លែងដែលគេបញ្ជូនលិខិតស្នាមផ្លូវច្បាប់ជាអន្តរជាតិក្នុងគោលបំណងផ្តន្ទាទោស ការ បញ្ជូនត្រូវធ្វើអោយមានប្រសិទ្ធភាពយ៉ាងរូសរាន់ ចំពោះគណៈគ្រប់គ្រងដែលជ្រើសរើសដោយភាគីទាំងអស់

តំរូវការនេះ ត្រូវគ្មានបុរេនិច្ឆ័យដល់សិទ្ធិរបស់ភាគីណាមួយដើម្បីតំរូវអោយគេបញ្ជូនលិខិតស្នាមផ្លូវច្បាប់នោះ អោយខ្លួនតាមរយៈអង្គទូតឡើយ ។

## មាត្រា៣៦

### បញ្ញត្តិព្រហ្មទណ្ឌ

១- ដោយការកំរិតដោយរដ្ឋធម្មនុញ្ញរបស់ខ្លួន ភាគីនិមួយៗត្រូវចាប់ប្រើប្រាសវិធានការទាំងអស់នោះក៏ដូចជា នឹងចាំបាច់ដល់ការដាំដុះ ផលិតផល ការផលិត និស្សារណកម្ម ការរៀបចំ ការមានជាកម្មសិទ្ធិ ការផ្តល់អោយ ការផ្តល់អោយលក់ ការបែងចែក ការទិញ ការលក់ ការចែកចាយតាមមធ្យោបាយណាក៏ដោយ ការនាំចេញសារ លិខិតទូរលេខ លិខិតទូរលេខឆ្លងកាត់ ការដឹកជញ្ជូន អាហរ័ណ និង និហរ័ណ ថ្នាំញៀនទាំងអស់ផ្ទុយទៅនឹងបទបញ្ញត្តិនៃអនុសញ្ញានេះហើយសកម្មភាពដទៃទៀតណាក៏ដោយដែលជាទស្សនៈរបស់ភាគីណាមួយផ្ទុយនឹងបញ្ញត្តិនៃអនុសញ្ញានេះ ត្រូវជាបទល្មើសដែលអាចផ្តន្ទាទោសនៅពេលណាត្រូវបានប្រព្រឹត្តជាអន្តរជាតិហើយបទល្មើសដ៏ធ្ងន់ធ្ងរនោះត្រូវអាចនឹងមានការផ្តន្ទាទោសគ្រប់

គ្រាន់ពិសេសដោយឡែកដោយដាក់គុក ការផ្តន្ទាទោសផ្សេងទៀតដោយដកហូតសិទ្ធិសេរីភាព ។

២- ដោយមានការកំរិតដោយរដ្ឋធម្មនុញ្ញរបស់ខ្លួនរបស់ភាគីមួយ ប្រព័ន្ធច្បាប់ និងច្បាប់ក្នុងស្រុករបស់ខ្លួន

ក- (i) បទល្មើសនិមួយៗដែលបានរៀបរាប់នៅក្នុងកថាខ័ណ្ឌ១ បើបានប្រព្រឹត្តនៅក្នុងប្រទេសផ្សេងៗគ្នាត្រូវ ចាត់ទុកជាបទល្មើសដោយឡែកពីគ្នា ។

(ii) ការចូលរួមដោយចេតនា ការរួមគំនិតដើម្បីប្រព្រឹត្តិ ការប៉ុនប៉ងប្រព្រឹត្តិ និង ទង្វើណាមួយនៃបទល្មើសបែបហ្នឹង ហើយនិងអំពើដែលរៀបចំបំរុងទុក និង ប្រតិបត្តិការហិរញ្ញវត្ថុ ជាប់ទាក់ទងនឹងបទល្មើសដែលមាន ចែងក្នុងមាត្រានេះត្រូវជាបទល្មើសដែលអាចផ្តន្ទាទោស ដូចដែលបានចែងក្នុងកថាខ័ណ្ឌ១ ។

(iii) ការកាត់ទោសក្រៅប្រទេសចំពោះបទល្មើសបែបហ្នឹង ត្រូវយកមកគិតពិចារណាដល់គោលបំណងនៃការបង្កើតអោយមានបទល្មើសដែលជាទំលាប់កើតមានឡើងវិញ ហើយ

(iv) ដោយយោងដល់បទល្មើសដ៏ធ្ងន់ធ្ងរ ពីមុនដែលបានប្រព្រឹត្តិឡើងដោយទាំងជាតិ និងជនបរទេសនោះ ត្រូវកាត់ទោសដោយភាគីដែលបទល្មើសបានប្រព្រឹត្តិឡើងក្នុងទឹកដីនោះ រឺ ដោយភាគីដែលជនល្មើសគេរក ឃើញនៅក្នុងទឹកដីនោះ ប្រសិនបើបត្យាប័នមិនអាចទទួលយកបាន ដោយអនុលោមទៅតាមច្បាប់នៃភាគី នោះអនុវត្ត ប្រសិនបើមិនបានកាត់ទោសជនល្មើសជាស្រេច និង ផ្តល់ការវិនិច្ឆ័យទោស .

ខ- ចង់បានថាបទល្មើស ដែលមានចែងក្នុងកថាខ័ណ១ និង កថាខ័ណ្ឌ ( ក ) ( ii ) ត្រូវរាប់បញ្ចូលថាជាបទល្មើសបត្យាប័ន ក្នុងសន្ធិសញ្ញាបត្យាប័នណាមួយដែលបានធ្វើឡើង រឺអាចធ្វើឡើងពីនេះតទៅរវាងភាគីណាមួយ និង ដូចជារវាងភាគីណាដែលមិនធ្វើបត្យាប័នដែលដាក់លក្ខខណ្ឌលើ ការមានសិទ្ធសញ្ញា រឺ បដិការ បានផ្តល់អោយដោយអនុលោមទៅតាមច្បាប់ដែលភាគីនោះអនុវត្ត ហើយបានចែងទៀតថា ភាគីនោះ ត្រូវមានសិទ្ធិបដិសេធមិនព្រមធ្វើអោយមានឡើងនូវការចាប់ខ្លួន រឺ ផ្តល់បត្យាប័នក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចចាត់ថាបទល្មើសនោះមិនធ្ងន់ធ្ងរ ។

៣. បទបញ្ញត្តិនៃមាត្រានេះ ត្រូវឋិតនៅក្រោមបញ្ញត្តិនៃច្បាប់ព្រហ្មទ័ណ្ឌរបស់ភាគីដែលពាក់ព័ន្ធស្តីអំពីបញ្ហាយុត្តាធិការ ។

៤. មិនមានអ្វីនៅក្នុងមាត្រានេះត្រូវប៉ះពាល់ដល់គោលការណ៍ថា បទល្មើសដែលបានយោងត្រូវកំណត់និយមន័យ ចោទប្រកាន់ និង ផ្តន្ទាទោសស្របតាមច្បាប់ក្នុងស្រុករបស់ភាគីទេ ។

## មាត្រា ៣៧

### ការចាប់ និង ការរឹបអូស

គ្រឿងញៀន សារធាតុ និង ឧបករណ៍ណាក៏ដោយដែលប្រើ ឬ មានបំណងថាយកទៅប្រើដើម្បីប្រព្រឹតបទល្មើសដូចមានចែងក្នុងមាត្រា ៣៦ ត្រូវធ្វើការចាប់ និង រឹបអូស ។

## មាត្រា ៣៨

### ការព្យាបាលអ្នកញៀនគ្រឿងញៀន

១. ភាគីត្រូវផ្តល់ការយកចិត្តទុកដាក់ពិសេសដល់ការផ្តល់ឧបករណ៍សំរាប់ការព្យាបាល តាមផ្នែកវេជ្ជសាស្ត្រ ការថែរទាំ និង ការស្តារនិតិសមប្បទាអ្នកញៀនគ្រឿងញៀន ។

២. ប្រសិនបើភាគីមួយមានបញ្ហាធ្ងន់ធ្ងរអំពីការញៀនគ្រឿងញៀន ហើយស្ថានភាពសេដ្ឋកិច្ចរបស់ខ្លួនអំណោយផលចង់បានថាភាគីនោះបង្កើតអោយមានឧបករណ៍សមស្របសំរាប់ការព្យាបាល ប្រកបដោយប្រសិទ្ធភាពចំពោះអ្នកញៀនគ្រឿងញៀន ។

## មាត្រា ៣៩

### ការអនុវត្តនីតិវិធានការគ្រប់គ្រងជាតិដែលតឹងរឹងជាងការកំណត់ក្នុងអនុសញ្ញានេះ

ទោះបីជាមានអ្វីៗក្នុងអនុសញ្ញានេះ ភាគីត្រូវមានសិទ្ធិអនុម័តវិធានការតឹងរឹងថែមទៀត ឬ តឹងរឹងជាងអ្វី ដែលមានចែងក្នុងក្នុងអនុសញ្ញានេះ និង ជាពិសេសទាក់ទងនឹងការរៀបចំតារាង III ឬ គ្រឿងញៀនក្នុងតារាង ២ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ ឬ វិធានការនៃការត្រួតពិនិត្យទាំងឡាយណាដែលអាចអនុវត្តបានចំពោះគ្រឿងញៀនក្នុងតារាង I ដោយតាមគំនិតរបស់ខ្លួនមានសារៈសំខាន់ ឬ ចង់បានសំរាប់ការការពារសុខភាព ឬ សុខមាលភាពសាធារណៈ ។

## មាត្រា ៤០

### ភាសារបស់អនុសញ្ញា និង និតិវិធីក្នុងការចុះហត្ថលេខា, ការធ្វើសច្ចាប្រណ៍ និង ការទទួលយក

១. ភាសាចិន បារាំង រុស្ស៊ី និងភាសាអេស្ប៉ាញក្នុងអនុសញ្ញានេះមានតំលៃដើមស្មើៗគ្នា នឹងត្រូវបើកចំហអោយចុះហត្ថលេខារហូតដល់ថ្ងៃ ១ ខែ សីហា ១៩៦១ ក្នុងនាមជាសមាជិករបស់អង្គការសហប្រជាជាតិ ឬ រដ្ឋដែលមិនមែនជាសមាជិកដែលជាភាគីមួយទៅនឹងលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬ សមាជិករបស់ភ្នាក់ងារជំនាញរបស់អង្គការសហប្រជាជាតិ ឬ រដ្ឋផ្សេងៗទៀត ដែលក្រុមប្រឹក្សាអាចអញ្ជើញអោយធ្វើជាភាគី ។

២. អនុសញ្ញានេះត្រូវដាក់អោយធ្វើសច្ចាប្រណ៍ ។ លិខិតតុបករណ៍នៃការធ្វើសច្ចាប្រណ៍ត្រូវដាក់ដំកល់ជាមួយនឹងអគ្គលេខាធិការ ។

៣. អនុសញ្ញានេះត្រូវបើកចំហរបន្ទាប់ពី ១ សីហា ១៩៦១ សំរាប់ការទទួលយកដោយរដ្ឋដែលមានយោងក្នុងកថាខណ្ឌ ១ ។ លិខិតតុបករណ៍នៃការទទួលយកត្រូវដាក់ដំកល់ជាមួយនឹងអគ្គលេខាធិការ ។

## មាត្រា ៤១

### ការចូលជាធរមាន

១. អនុសញ្ញានេះត្រូវចូលជាធរមាន ៣០ ថ្ងៃក្រោយពីកាលបរិច្ឆេទនៃលិខិតតុបករណ៍ ឬ ការទទួលយកទី ២០ ត្រូវបានដាក់ដំកល់ស្របតាមមាត្រា ៤០ ។

២. ទាក់ទងនឹងរដ្ឋផ្សេងៗទៀតដែលដាក់ដំកល់លិខិតតុបករណ៍អំពីការធ្វើសច្ចាប្រណ៍ ឬ ការទទួលយកក្រោយកាលបរិច្ឆេទនៃការការដាក់ដំកល់នៃលិខិតតុបករណ៍ទី២០ដែលបានលើកឡើង អនុសញ្ញានេះ ត្រូវចូលជាធរមាននៅ ៣០ ថ្ងៃក្រោយពីការដាក់ដំកល់របស់រដ្ឋនោះនូវលិខិតតុបករណ៍នៃការធ្វើ សច្ចាប្រណ៍ ឬ ការទទួលយករបស់ខ្លួន ។

## មាត្រា ៤២

### ដែនអនុវត្ត

អនុសញ្ញានេះ ត្រូវអនុវត្តចំពោះដែនដីទាំងអស់ក្នុងទំនាក់ទំនងអន្តរជាតិដែលភាគីណាមួយទទួលខុសត្រូវលើក លែងតែក្នុងករណីដែលតំរូវអោយមានការសុំការឯកភាពជាមុនពីដែនដីនោះដោយធម្មនុញ្ញរបស់ភាគី ឬ របស់ដែនដីដែលពាក់ព័ន្ធ ឬ ដោយគយ ។ ក្នុងករណីនេះភាគីធានាអោយបាននូវការឯកភាពដែលត្រូវការអំពីដែនដី ក្នុងរយៈពេលមួយដ៏ខ្លីតាមដែលអាចធ្វើទៅបាន និង នៅពេលទទួលបានការឯកភាពទាំងនោះ ភាគីត្រូវជូនដំណឹងដល់អគ្គលេខាធិការ ។ អនុសញ្ញានេះត្រូវអនុវត្តចំពោះដែនដីដែលមានដាក់ក្នុងសេចក្តីជូនដំណឹងនោះចាប់ពីកាលបរិច្ឆេទទទួលរបស់អគ្គលេខាធិការ ។ ក្នុងករណីដែលមិនបានទទួលការឯកភាពពីដែនដី ភាគីពាក់ព័ន្ធ ត្រូវប្រកាសពីទីតាំងដែលត្រូវអនុវត្តអនុសញ្ញានេះនៅពេលចុះហត្ថលេខាការធ្វើសច្ចាប្រណ៍ ឬ ការទទួលយក ។

## មាត្រា ៤៣

### ដែនដីសំរាប់គោលបំណងនៃមាត្រា ១៩, ២០, ២១, និង ៣១

១ ភាគីណាក៏ដោយអាចជូនដំណឹងដល់អគ្គលេខាធិការថា ដើម្បីគោលបំណងរបស់មាត្រា ១៩, ២០, ២១, និង ៣១ ដែនដីមួយក្នុងចំណោមដែនដីរបស់ខ្លួនត្រូវបែងចែកជាពីរ ឬ ច្រើន ឬ ក៏អាចថាដែនដីរបស់ខ្លួន

ពីរ ឬ ច្រើនត្រូវដាក់បញ្ចូលអោយទៅតែមួយ ។

២. ភាគីពីរ ឬ ច្រើនអាចជូនដំណឹងដល់អគ្គលេខាធិការថា ជាលទ្ធផលនៃការបង្កើតសមាគមគយមួយរវាងពួកគេ ភាគីទាំងនោះនឹងជាដែនដីតែមួយសំរាប់គោលបំណងនៃមាត្រា ១៩. ២០. ២១. និង ៣១ ។

៣. រាល់ការជូនដំណឹងតាមកថាខណ្ឌ ១ ឬ ២ ខាងលើត្រូវមានប្រសិទ្ធិភាពចាប់ពី ១ មករា នៃឆ្នាំក្រោយពីការធ្វើសច្ចាប្រ័នមួយឆ្នាំ ។

## មាត្រា ៤៤
## ការបញ្ចប់សន្ធិសញ្ញាអន្តរជាតិមុន

១. ក្រោយពីចូលជាធរមានរវាងភាគីក្នុងអនុសញ្ញានេះ បញ្ញត្តិនៃអនុសញ្ញានេះត្រូវបញ្ចប់ និង ជំនួសបញ្ញត្តិនៃសន្ធិសញ្ញាខាងក្រោម :

(ក) អនុសញ្ញាអាភៀនអន្តរជាតិ បានចុះហត្ថលេខានៅ ទីក្រុងឡាអេ នៅថ្ងៃ ២៣ មករា ១៩១២

(ខ) កិច្ចព្រមព្រៀងទាក់ទងនឹងការផលិត ការធ្វើជំនួញក្នុងស្រុក និង ការប្រើប្រាស់អាភៀនផ្សំ បានចុះហត្ថលេខានៅទីក្រុង ហ្សឺណែវ នៅថ្ងៃទី ១១ កុម្ភៈ ១៩២៥

(គ) អនុសញ្ញាអាភៀនអន្តរជាតិ ចុះហត្ថលេខានៅ ហ្សឺណែវ នៅថ្ងៃ ១៩ កុម្ភៈ ១៩២៥

(ឃ) អនុសញ្ញាសំរាប់ការកំរិតការផលិត និង ការគ្រប់គ្រងលើការចែកចាយគ្រឿងញៀនស្រវឹង ចុះហត្ថលេខានៅ ហ្សឺណែវ នៅថ្ងៃ ១៣ ខែ កក្កដា ១៩៣១

(ង) កិច្ចព្រមព្រៀងសំរាប់ការត្រួតពិនិត្យការជក់អាភៀននៅចុងបូព៌ា ចុះហត្ថលេខានៅបាងកក នៅថ្ងៃ ២៧ ខែវិច្ឆិកា ១៩៣១

(ច) ពិធីសារសន្និចុះហត្ថលេខានៅ លេកសាក់សេស នៅថ្ងៃ ១១ ធ្នូ ១៩៤៦ ដោយធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀង អនុសញ្ញា និង ពិធីសារសន្និលើគ្រឿងញៀនស្រវឹងដែលធ្វើឡើងនៅ ឡាអេ ថ្ងៃ ២៣ មករា ១៩១២ នៅ ហ្សឺណែវ ១១ កុម្ភៈ ១៩២៥ និង ១៩ មករា ១៩២៥ និង ១៣ កក្កដា ១៩៣១ នៅបាងកក ២៧ វិច្ឆិកា ១៩៣១ និង នៅហ្សឺណែវ ២៦ មិថុនា ១៩៣៦ លើកលែងតែវាប៉ះពាល់ដល់អនុសញ្ញាដែលដាក់ឈ្មោះចុងក្រោយ

(ឆ) អនុសញ្ញា និង កិច្ចព្រមព្រៀងដែលមានយោងក្នុងអនុកថាខណ្ឌ (ក) ទៅ (ង) ដូចបានធ្វើវិសោធនកម្មដោយពិធីសារសន៍នៃឆ្នាំ ១៩៤៦ ដូចមានយោងក្នុងអនុកថាខណ្ឌ (ច)

(ជ) ពិធីសារសន៍ចុះហត្ថលេខានៅ ប៉ារីស ថ្ងៃ ១៩ វិច្ឆិកា ១៩៤៨ ដោយដាក់បញ្ចូលក្រោមការត្រួតពិនិត្យគ្រឿងញៀនអន្តរជាតិខាងក្រៅវិសាលភាពនៃអនុសញ្ញានៃ ១៣ កក្កដា ១៩៣១ សំរាប់ការដាក់កំរិតលើការផលិត និង ការគ្រប់គ្រងការចែកចាយគ្រឿងញៀនស្រវឹងដូចបានធ្វើវិសោធនកម្មដោយពិធីសារសន៍ដែលបានចុះហត្ថលេខានៅ លេកសាក់សេស នៅថ្ងៃ ១១ ធ្នូ ១៩៤៦

(ឈ) ពិធីសារសន៍សំរាប់ការកំរិត និង ការគ្រប់គ្រងលើការដាំដុះដើមថ្នាំញៀន ការផលិត ការធ្វើជំនួញជាអន្តរជាតិ ឬ លក់ដុំ និង ការប្រើប្រាស់អាភៀន ដែលបានចុះហត្ថលេខានៅ ញូយកនៅថ្ងៃ ២៣ មិថុនា ១៩៥៣ ប្រសិនបើពិធីសារសន៍នោះចូលជាធរមាន ។

២. ក្រោយពីការចូលជាធរមាននៃអនុសញ្ញានេះ មាត្រា ៩ នៃអនុសញ្ញាសំរាប់ការបង្ក្រាបចរាចរខុសច្បាប់នូវគ្រឿងញៀនដែលគ្រោះថ្នាក់ ដូចបានចុះហត្ថលេខានៅ ហ្សឺណែវ នៅថ្ងៃ ២៦ ខែ កក្កដា ១៩៣៦ រវាងភាគីនៃកិច្ចព្រមព្រៀងនោះដែលជាភាគីក្នុងអនុសញ្ញានេះ ត្រូវបញ្ចប់ ហើយត្រូវជំនួសដោយកថាខណ្ឌ ២ (ខ) នៃមាត្រា ៣៦ របស់អនុសញ្ញានេះប្រសិនបើភាគីមួយ តាមរយៈការជូនដំណឹងទៅអគ្គលេខាធិការអាចចូលជាធរមាននូវមាត្រា ៩ ដែលបានលើកឡើង ។

## មាត្រា ៤៥

## អន្តរបញ្ញត្តិ

១. តួនាទីរបស់ក្រុមប្រឹក្សាភិបាលដែលមានចែងក្នុងមាត្រា៩ អនុវត្តជាបណ្តោះអាសន្នដោយក្រុមប្រឹក្សាកណ្តាលអចិន្ត្រៃយ៍តាមជំពូក ៦ នៃអនុសញ្ញាដែលមានចែងក្នុងមាត្រា ៤៤ (គ) ដូចបានធ្វើវិសោធនកម្មរួចហើយ ហើយដោយអង្គការត្រួតពិនិត្យដែលមានសមាសភាពតាម ជំពូក ២ នៃអនុសញ្ញាដូចមានចែងក្នុងមាត្រា ៤៤ (ឃ) ដែលបានធ្វើវិសោធនកម្មរួចហើយដូច ដែលមុខងារតំរូវចាប់តាំងពីពេលចូលជាធរមាននៃអនុសញ្ញានេះ (មាត្រា ៤១ កថាខណ្ឌ ១) ។

២. ក្រុមប្រឹក្សាត្រូវកំណត់កាលបរិច្ឆេតជាក់លាក់ដែលក្រុមប្រឹក្សាភិបាលថ្មីដូចមានយោងក្នុងមាត្រា ៩ ត្រូវចូលកាន់ភារៈកិច្ចរបស់ខ្លួន ។ ចាប់តាំងពីកាលបរិច្ឆេតនោះមកក្រុមប្រឹក្សាភិបាលត្រូវអនុវត្តតួនាទីរបស់

ក្រុមប្រឹក្សាភិបាលកណ្តាលអចិន្ត្រៃយ៍ និង អង្គការត្រួតពិនិត្យដូចមានយោងក្នុង កថាខណ្ឌ ១ ចំពោះភាគីរដ្ឋក្នុងសន្ធិសញ្ញាដែលមានរាយក្នុងមាត្រា ៤៤ ថាមិនមែនជាភាគីក្នុង អនុសញ្ញានេះ ។

## មាត្រា ៤៦

### ការដកខ្លួន

១. បន្ទាប់ពីបញ្ចប់នៃរយៈពេល ២ ឆ្នាំចាប់ពីកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ (មាត្រា ៤១ កថាខណ្ឌ ១) ក្នុងនាមខ្លួនផ្ទាល់ ឬ តំណាងអោយដែនដីមួយដែលមានការទទួលខុសត្រូវ ជាអន្តរជាតិ ហើយបានដកការឯកភាពរបស់ខ្លួនស្របតាមមាត្រា ៤២ ភាគីណាក៏អាចប្រកាសដកខ្លួន អនុសញ្ញានេះ ដោយលិខិតតុបករណ៍មួយជាលាយលាក់អក្សរដាក់ដំកល់ជាមួយអគ្គលេខាធិការ ។

២. ការប្រកាសដកខ្លួន ប្រសិនបើទទួលបានដោយអគ្គលេខាធិការនៅថ្ងៃ ឬ មុនថ្ងៃទី ១ នៃ ខែ កក្កដា ក្នុងឆ្នាំណាមួយត្រូវចូលជាធរមាននៅថ្ងៃទី ១ ខែ មករា ក្នុងឆ្នាំមុននេះ ហើយប្រសិនបើបានទទួល បន្ទាប់ពីថ្ងៃទី ១ ខែ កក្កដា ត្រូវចូលជាធរមានដូចដែលបានទទួលនៅថ្ងៃ ឬ មុនថ្ងៃទី ១ នៃខែ កក្កដា ក្នុងឆ្នាំបន្ទាប់ ។

៣. អនុសញ្ញានេះត្រូវបញ្ចប់ប្រសិនបើដោយសារលទ្ធផលនៃការដកខ្លួនធ្វើឡើងស្របតាមកថាខណ្ឌ ១ លក្ខខណ្ឌនៃការចូលជាធរមានដូចមានចែងក្នុងមាត្រា ៤១ កថាខណ្ឌ ១ ឈប់មានអត្ថិភាព ។

## មាត្រា ៤៧

### វិសោធនកម្ម

១. ភាគីណាក៏ដោយអាចស្នើអោយធ្វើវិសោធនកម្មលើអនុសញ្ញានេះ ។ ឯកសារនៃការធ្វើ វិសោធនកម្ម និង ហេតុផលនៃការធ្វើបែបនេះត្រូវជូនដំណឹងដល់អគ្គលេខាធិការដែលត្រូវជូន ដំណឹងបន្តទៅភាគី និង ទៅក្រុមប្រឹក្សា ។ ក្រុមប្រឹក្សាអាចសំរេចថា :

(ក) ត្រូវរៀបចំធ្វើសន្និសីទស្របតាមមាត្រា ៦២ កថាខណ្ឌ ៤ នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិដើម្បីពិចារណាលើការធ្វើវិសោធនកម្មដែលបានស្នើ ឬ

(ខ) ត្រូវសាកសួរដល់ភាគីតើពួកគេទទួលយកសំណើសុំធ្វើវិសោធនកម្ម និង ក៏សុំអោយដាក់បញ្ជូនទៅក្រុមប្រឹក្សាដើម្បីស្នើសុំមតិយោបល់លើសំណើនោះ ។

២. ប្រសិនបើសំណើរសុំធ្វើវិសោធនកម្មនោះត្រូវបានចែកជូនតាមកថាខណ្ឌ ១ (ខ)នៃមាត្រានេះមិនបានទទួលការបដិសេធន៍ពីភាគីណាមួយក្នុងអំឡុងពេល ១៨ ខែបន្ទាប់ពីបានបញ្ជូនសំណើនោះ ត្រូវមានប្រសិទ្ធិភាពចាប់ពីពេលនោះតទៅ ។ ផ្ទុយទៅវិញ ប្រសិនបើសំណើសុំធ្វើវិសោធនកម្មនោះ ត្រូវបានភាគីណាមួយបដិសេធ ក្រុមប្រឹក្សាអាចសំរេចតាមមតិយោបល់ដែលបានទទួលពីភាគី ទោះបីជាត្រូវរៀបចំធ្វើសន្និសីទដើម្បីពិចារណាលើការធ្វើវិសោធនកម្មនោះក៏ដោយ ។

## មាត្រា ៤៨

### ជំលោះ

១. ប្រសិនបើមានជំលោះដែលពាក់ពន្ធ័រវាងភាគីពីរ ឬ ច្រើនទាក់ទងនឹងការបកស្រាយខុស ឬការអនុវត្តអនុសញ្ញានេះ ភាគីដែលបានលើកឡើងត្រូវប្រឹក្សារួមគ្នាដោយផ្អែកលើទស្សនៈនៃការដោះស្រាយជំលោះតាមរយៈការចចារ ការស៊ើបអង្កេត ការសំរុះសំរួល ការផ្សះផ្សារ និង ឧបាស្រ័យចំពោះអង្គការតំ បន់ ដំណើរការតុលាការ ឬ មធ្យោបាយអហឹង្សាផ្សេងៗទៀតតាមជំរើសរបស់ពួកគេ ។

## មាត្រា ៤៩

### ការបំរុងទុកបណ្តោះអាសន

១- នៅពេលចុះហត្ថលេខា ធ្វើសច្ចានុម័ត រឺ យល់ព្រម ភាគីមួយអាចរកបំរុងនូវសិទ្ធិ ដើម្បីអនុញ្ញាតជាបណ្តោះអាសន្ន នៅក្នុងទឹកដីណាមួយរបស់ខ្លួននូវ :

ក- ការប្រើអាភៀនខាងវិស័យសុខាភិបាលដោយមិនច្បាស់លាស់ ។

ខ- ការជក់អាភៀន

គ- ការបរិភោគស្លឹកកូកា

ឃ- ការប្រើកញ្ឆា , ជ័រកញ្ឆា និស្សារណា និង ជាតិប្រេងៗ របស់កញ្ឆា ក្នុងគោលបំណងក្រៅពីផ្នែកសុខាភិបាល

ង- ផលិតកម្ម ការផលិត និង ការជួញថ្នាំញៀន ដែលសំដៅលើចំនុច ( ក ) រហូតដល់ចំនុច ( ឃ ) សំរាប់ គោលបំណងដូចដែលបានរៀបរាប់នៅក្នុងនោះ ។

២- ការទុកបំរុង នៅក្នុងកថាខ័ណ្ឌ ១ ត្រូវតែមានការកំរិតដូចតទៅ :

ក- សកម្មភាពទាំងឡាយដែលបានរៀបរាប់ ក្នុងកថាខ័ណ្ឌ ១ អាចផ្តល់អាជ្ញាអោយត្រឹមតែកំរិតដែលជាទំលាប់ប្រពៃណីក្នុងទឹកដីនោះ ដោយគោរពទៅតាមការបំរុងទុកដែលបានធ្វើ ហើយដែលបានអនុញ្ញាតអោយ នៅ ថ្ងៃ ទី ១ ខែ មករា ឆ្នាំ១៩៦៤ ។

ខ- គ្មានការនាំចេញថ្នាំញៀន ដូចដែលបានចែង ក្នុងកថាខ័ណ្ឌ ១ សំរាប់គោបំណងដែលបានរៀបរាប់ដូចនៅក្នុងនោះ អាចអនុញ្ញាតអោយភាគីក្រៅមួយ រឺ អោយទឹកដីមួយដែលមិនអនុវត្តអនុសញ្ញានេះក្នុងមាត្រា ៤២ ។

គ- ជនបែបនោះតែមួយគត់អាចអនុញ្ញាតអោយជក់អាភៀន ដូចដែលបានចុះបញ្ជី ដោយអាជ្ញាធរដែលមានសមត្ថកិច្ចចាប់ពីថ្ងៃទី ១ ខែ មករា ឆ្នាំ១៩៦៤ ។

ឃ- ការប្រើប្រាស់អាភៀនក្នុងវិស័យវេជ្ជសាស្ត្រត្រូវទុកជានិរាករណ៍ ក្នុងរយៈពេល ១៥ឆ្នាំ ចាប់តាំងពីអនុញ្ញា នេះចូលជាធរមានដូចដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៤១ ។

ង- ការបរិភោគស្លឹកកូកាត្រូវចូលជានិរាករណ៍ក្នុងរយៈពេល ២៥ឆ្នាំ ចាប់តាំងពីអនុញ្ញានេះចូលជាធរមានដូចដែលបានចែងកថាខ័ណ្ឌ ១ នៃមាត្រា ៤១ ។

ច- ការប្រើកញ្ឆាសំរាប់គោលបំណង ក្រៅពីផ្នែកវិទ្យាសាស្ត្រ និង សុខាភិបាល ត្រូវបញ្ឈប់ភ្លាមតាមលទ្ធភាពដែលអាចធ្វើបានក្នុងរយៈពេល ២៥ឆ្នាំ ចាប់ពីអនុសញ្ញានេះចូលជាធរមាន ទោះបីជាករណីណាក៏ដោយ ដូចដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃ មាត្រា ៤១ ។

ឆ- ផលិតកម្ម និង ការផលិត និង ការធ្វើជំនួញថ្នាំញៀន ដូចដែលមានចែងក្នុងកថាខ័ណ្ឌ សំរាប់គោលបំណង ប្រើណាមួយដូចបានរៀបរាប់នៅក្នុងនោះ ត្រូវកាត់បន្ថយជាចុងក្រោយ ធ្វើអោយទៅជានិរាករណ៍ ដូចការ កាត់បន្ថយ និង ទុបស្កាត់នៃការប្រើប្រាស់បែបនោះ ។

៣- ភាគីមួយដែលមិនឯកភាពតាមកថាខណ្ឌ ១ ត្រូវ :

ក- បញ្ចូលទៅក្នុងបញ្ជីប្រចាំឆ្នាំ ដើម្បីផ្តល់ជូនទៅអោយអគ្គលេខាធិការ ដោយអនុលោមទៅតាម មាត្រា ១៨ កថាខ័ណ្ឌ១ (ក) ប្រវត្តិនៃការកើនឡើងបានធ្វើនៅក្នុងឆ្នាំមុនសំដៅទៅលើការទុបស្កាត់នៃ ការប្រើប្រាស់ផលិតកម្ម ការផលិត រឺ ការជួញ មានចែងនៅក្នុងកថាខ័ណ្ឌ ១ ហើយ

ខ- ផ្តល់ជូនដល់ក្រុមប្រឹក្សាភិបាលនូវការប៉ាន់ស្មានដាច់ៗពីគ្នា (មាត្រា ១៩) ហើយនិងការបញ្ជូនស្ថិតិ (មាត្រា ២០) ដោយគោរពទៅតាមសកម្មភាពបំរុងទុក នៅក្នុងបែបបទ និង ទ្រង់ទ្រាយដែលបានរៀប រាប់ជូនដោយក្រុមប្រឹក្សាភិបាល ។

៤- ក/- ប្រសិនបើភាគីមួយបង្កើតការបំរុងទុក នៅក្នុងកថាខ័ណ្ឌ ១ ខកខានមិនបានផ្តល់ជូន :

(i) របាយការណ៍ ដូចបានចែងនៅក្នុងកថាខ័ណ្ឌ ៣ (ក) ក្នុងរយៈ ៦ខែ បន្ទាប់ពីការបញ្ចប់ ឆ្នាំទាក់ទងទៅនឹងពតិមាន

(ii) ការប៉ាន់ស្មានដូចបានចែងក្នុងកថាខ័ណ្ឌ ៣ (ខ) ក្នុងរយៈពេល ៣ខែ បន្ទាប់ពីកាល បរិច្ឆេទបានកំណត់ សំរាប់គោលបំណងនោះ ដោយក្រុមប្រឹក្សាភិបាល ដោយអនុលោម ទៅតាមមាត្រា ១២ កថាខ័ណ្ឌ ១

(iii) ស្ថិតិដូចមានចែងនៅក្នុងកថាខ័ណ្ឌ ៣ (ខ) ក្នុងកំឡុងពេល ៣ខែ បន្ទាប់ពីគេគ្រោងធ្វើ ការកំណត់ការបរិច្ឆេទ ដោយអនុលោមទៅតាមមាត្រា ២០ កថាខ័ណ្ឌ ២ ក្នុងករណី ណាមួយដែលក្រុមប្រឹក្សាភិបាល និង អគ្គលេខាធិការត្រូវបញ្ជូនទៅអោយភាគីពាក់ ព័ន្ធនូវសេចក្តីជូនដំណឹងនៃការផ្អាកមួយ ហើយត្រូវស្នើសុំយកពតិមានបែបនោះក្នុង កំឡុងពេល ៣ខែ បន្ទាប់ពីថ្ងៃដែលទទួលបានសេចក្តីប្រកាសជូនដំណឹងនោះ ។

ខ- ប្រសិនបើភាគីនោះខកខានមិនបានធ្វើទៅតាមអំឡុងពេលដំណើរសុំរបស់ក្រុមប្រឹក្សាភិបាល រឺ អគ្គ-លេខាធិការ ក្នុងរយៈពេលនោះ ការមិនឯកភាពដែលធ្វើឡើងនៅក្នុងកថាខ័ណ្ឌ ១ មិនមានប្រសិទ្ធ ភាពទៀត ឡើយ ។

៥- រដ្ឋមួយបានបង្កើតការបំរុងទុក ឡើងដោយសេចក្តីប្រកាសជូនដំណឹងដែលសរសេរជាលាយលាក់អក្សរ អាចដកផ្នែកមួយ រឺ ទាំងអស់នៃការបំរុងទុករបស់ខ្លួនបាន ក្នុងករណីណាក៏ដោយ ។

## មាត្រា ៥០

### ការបំរុងផ្សេងទៀត

១. គ្មានការបំរុងណាក្រៅពីការបំរុងទុកដែលបានធ្វើឡើង ដោយអនុលោមទៅតាមមាត្រាទី ៤៩ ឬទៅតាមកថាខ័ណ្ឌខាងក្រោមត្រូវបានអនុញ្ញាតអោយឡើយ ។

២. នៅពេលចុះហត្ថលេខា អោយសច្ចានុម័តឬយល់ព្រម ភាគីណាមួយក៏អាចធ្វើការបំរុងដោយគោរពទៅតាមបទបញ្ញត្តិដូចតទៅនៃអនុសញ្ញានេះ : មាត្រា ១២ កថាខណ្ឌ២ និង ៣ មាត្រា ១៣កថាខណ្ឌ ២ មា១៤ កថាខណ្ឌ ១ និង ២ មាត្រា៣១ កថាខ័ណ្ឌ ១(ខ) និង មាត្រា ៤៨ ។

៣. រដ្ឋមួយដែលមានបំណងចង់ក្លាយខ្លួនជាភាគីមួយ ប៉ុន្តែចង់បានអាជ្ញាដើម្បីធ្វើការបំរុងក្រៅពីការបំរុងដែលបានធ្វើឡើងដោយអនុលោមទៅតាម ខថាខ័ណ្ឌ ២ នៃមាត្រានេះ រឺ នៅតាមមាត្រា ៣៩ អាចជំរាបជូនដំណឹងដល់អគ្គលេខាធិការនូវចេតនាបែបនេះ ។ វៀរលែងតែការបំរុងនេះ បានជំនាស់ដោយ ១ភាគ៣ នៃរដ្ឋទាំងអស់ដែលបានអោយសច្ចានុម័ត រឺ យល់ព្រមចំពោះអនុសញ្ញានេះ មុនការបញ្ចប់អំឡុងពេល នោះត្រឹមចុងបញ្ចប់ ១២ខែ បន្ទាប់ពីកាលបរិច្ឆេត នៃការទំនាក់ទំនង ការបំរុង របស់អគ្គលេខាធិការ ដែលពាក់ព័ន្ធ នោះវាត្រូវចាត់ទុកថា គេអនុញ្ញាតអោយទោះបីគេយល់ថា រដ្ឋទាំងអស់ដែលបានជំទាស់ ចំពោះតំរូវ ការបំរុង មិនបានសន្មត់ជាមុនចំពោះរដ្ឋបំរុងនូវកាតព្វកិច្ចណាមួយនៅក្នុងអនុសញ្ញានេះ ដែលធ្វើអោយប្រែប្រួលដោយការបំរុងនោះ ។

៤. រដ្ឋដែលបានធ្វើការបំរុង ដកផ្នែកមួយនៃការបំរុងរបស់ខ្លួនរឺទាំងអស់នៅពេលណាក៏បានដោយធ្វើសេចក្តីប្រកាសជូនដំណឹងជាលាយល័ក្ខអក្សរ ។

## មាត្រា ៥១

### សេចក្តីប្រកាសជូនដំណឹង

អគ្គលេខាធិការត្រូវធ្វើសេចក្តីប្រកាសជូនដំណឹងទៅដល់រដ្ឋទាំងអស់ ដែលមានចែងនៅក្នុងកថាខ័ណ្ឌ ១ នៃមាត្រា ៤០ នូវ៖

ក- ហត្ថលេខា សច្ចានុម័ត និង ការយល់ព្រមដោយអនុលោមទៅតាមមាត្រា ៤០

ខ- កាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមានដោយអនុលោមទៅតាមមាត្រា ៤១

គ- ការប្រកាសមិនយល់ព្រមយ៉ាងឧឡារិក ដោយអនុលោមទៅតាមមាត្រា ៤៦ និង

ឃ- សេចក្តីថ្លែងការ និង សេចក្តីប្រកាសជូនដំណឹង នៅក្នុងមាត្រា ៤២ ៤៣ ៤៧ ៤៩ និង ៥០ ។

ដើម្បីទុកជាសាក្សី អ្នកដែលបានចុះហត្ថលេខាពីខាងក្រោម ដែលមានអាជ្ញាដោយត្រឹមត្រូវ បានចុះហត្ថលេខាលើអនុសញ្ញានេះ ក្នុងនាមជារដ្ឋាភិបាលរៀងៗខ្លួន

ធ្វើនៅទីក្រុងញ៉ូយក់ ថ្ងៃទី សាមសិប ខែ មិនា ឆ្នាំ មួយពាន់ប្រាំបួនរយហុកសិបមួយ តែមួយច្បាប់គត់ ដែលត្រូវតំកល់ទុកនៅបណ្ណសាររបស់អង្គការសហប្រជាជាតិ ហើយច្បាប់ថតចម្លងចេញពីច្បាប់ដើមដែលបញ្ជាក់ថាពិតនោះត្រូវបញ្ជូនទៅអោយគ្រប់សមាជិករបស់អង្គការសហប្រជាជាតិទាំងអស់និងរដ្ឋដទៃទៀតដែលមានចែងនៅក្នុងមាត្រា ៤០ កថាខ័ណ្ឌ ១ ។

តារាង

បញ្ជីឈ្មោះថ្នាំញៀនដែលបញ្ចូលក្នុងតារាង I

អាសេទីលមេតាដុល ( ៣-អាសេតុកស៊ី-៦-ឌីមេទីលអាមីណូ-៤ ៤-ឌីហ្វេនីលអិបតាន)

អាលីលប្រូឌីន ( ៣-អាលីល-១-មេទីល-៤-ហ្វេនីល-៤-ប្រូព្យូណុកស៊ីពីពេរីឌីន )

អាល់ហ្វាសេទីលមេតាដុល ( អាល់ហ្វា-៣-អាសេតុកស៊ី-៦-ឌីមេទីលអាមីណូ-៤ ៤-ឌីហ្វេីលអ៊ិបតាន)

អាល់ហ្វាមេប្រូឌីន ( អាល់ហ្វា-៣-អេទីល-១-មេទីល-៤-ហ្វេទីល-៤-ប្រូព្យូណុកស៊ីពីពេរីឌីន)

អាល់ហ្វាមេតាដុល ( អាល់ហ្វា-៦-ឌីមេទីលអាមីណូ-៤ ៤-ឌីហ្វេនីល-៣-អិបតាណុល)

អាល់ហ្វាប្រូឌីន ( អាល់ហ្វា-១ ៣-ឌីមេទីល-៤-ហ្វេនីល-៤-ប្រូព្យូណុកស៊ីពីពេរីឌីន)

អានីលេរីឌីន ( ១-ប៉ារ៉ា-អាមីណូហ្វេណេទីល-៤-ហ្វេនីលពីពេរីឌីន-៤-អាស៊ីដកាបុកស៊ីលិកអេទីលអេស្ទែរ)

បង់ហ្សេទីឌីន ( ១-(២-បង់ហ្ស៊ីឡុកស៊ីអេទីល)-៤-ហ្វេនីលពីពេរីឌីន-៤-អាស៊ីដកាបុកស៊ីលិកអេទីលអេស្ទែរ)

បង់ហ្ស៊ីលម័រហ្វីន ( ៣-បង់ហ្ស៊ីលម័រហ្វីន)

បេតាសេទីលមេតាដុល ( បេតា-៣-អាសេតុកស៊ី-៦-ឌីមេទីលអាមីណូ-៤ ៤-ឌីហ្វេនីលអ៊ិបតាន)

បេតាមេប្រូឌីន ( បេតា-៣-អេទីល-១-មេទីល-៤-ហ្វេនីល-៤-ប្រូព្យូណុកស៊ីពីពេរីឌីន)

បេតាមេតាដុល ( បេតា-៦-ឌីមេទីលអាមីណូ-៤ ៤-ឌីហ្វេនីល-៣-អ៊ិបតាណុល)

បេតាប្រូឌីន ( បេតា-១ ៣-ឌីមេទីល-៤-ហ្វេនីល-៤-ប្រូព្យូណុកស៊ីពីពេរីឌីន)

កញ្ឆា ជ័រកញ្ឆា និស្សារណា និងសារជាតិព្រឿង១របស់ដើមកញ្ឆា

ក្លូនីតាហ្សែន(២-ប៉ារ៉ា-ក្លរបង់ហ្ស៊ីល-១-ឌីអេទីលអាមីណូអេទីល-៥-នីត្រូបង់ហ្ស៊ីមីដាហ្សុល)

ស្លឹកកូកា

កូកាអ៊ីន ( អេទីលអេស្ទែរនៃបង់ហ្សូអ៊ីលិកហ្គូនីន)

កំហាប់ដើមអាភៀនក្រៀម ( ជាសារធាតុដែលទទួលបាននៅពេលដើមអាភៀនក្រៀមបានដាក់ចូលកែឆ្នៃដើម្បីធ្វើអោយជាតិអាល់កាឡូអ៊ីតរបស់វាឡើងខាប់ នៅពេលនោះគេផលិតបានសារធាតុបែបនេះយកទៅលក់បាន ) ។

ដេសូមរ៉ហ្វីន (ឌីអ៊ីដ្រូដេអុកស៊ីមរ៉ហ្វីន )

ដិកស្ត្រូម៉ូរ៉ាមីត ((+)-៤-[២-មេទីល-៤-អុកសូ-៣ ៣-ឌីហ្វេនីល-៤-( -១-ព្យ៉រ៉ូលីឌីនីល) ប៊ុយទីល] មរ៉ហ្វីន)

ឌីអំប្រូមីត (អ៊ិន-[២-មេទីលហ្វេនេទីលអាមីណូ ) ប្រូពីល ] ប្រូព្យូណានីលីត)

ឌីអេទីលទីអំប៊ុយតែន (៣-ឌីអេទីលអាមីណូ-១ ១-ឌី-(២ -ត្យេនីល) -១-ប៊ុយតែន)

ឌីអ៊ីដ្រូមរ៉ហ្វីន

ឌីមេណុកសាដុល (២-ឌីមេទីលអាមីណូអេទីល-១-អេតុកស៊ី-១ ១-ឌីហ្វេនីលអាសេតាត )

ឌីមេហ្វេបតាណុល (៦-ឌីមេទីលអាមីណូ-៤ ៤-ឌីហ្វេនីល-៣-អ៊ុបតាណុល)

ឌីមេទីលទីអំប៊ុយតែន (៣-ឌីមេទីលអាមីណូ-១ ១-ឌី-(២' -ត្យេនីល) -១-ប៊ុយតែន)

ឌីអុកសាហ្វេទីល ប៊ុយទីរាត (អេទីល ៤-មរ៉ហ្វូលីណូ-២ ២-ឌីហ្វេនីលប៊ុយទីរាត)

ឌីហ្វេណុកស៊ីឡាត (១-(៣-ស្យាណូ-៣ ៣-ឌីហ្វេនីលប្រូពីល) -៤-ហ្វេនីលពីពេរីឌីន-៤-អាស៊ីត កាបុកស៊ីលិក អេទីលអេស្ទែរ)

ឌីពីប៉ាណន (៤ ៤-ឌីហ្វេនីល-៦-ពិពេរីឌីន-៣-អ៊ុបតាណន)

អ៊ុកហ្គូនីន អេស្ទែរនិងផលិតផលមានដើមកំណើតពីអេស្ទែរ របស់វា ដែលបំលែងទៅជា អ៊ុកហ្គូនីន និងកូកាអ៊ីន

អេទីលមេទីលទីអំប៊ុយតែន (៣-អេទីលមេទីលអាមីណូ-១ ១-ឌី-(២' -ត្យេនីល) -១-ប៊ុយតែន)

អេតូនីតាហ្សែន (១-ឌីអេទីលអាមីណូអេទីល-២-ប៉ារ៉ា-អេតុកស៊ីបង់ហ្ស៊ីល-៥-នីត្រូបង់ហ្ស៊ីមីដាហ្សុល)

អេតុកសេរីឌីន (១-[២-(២-អ៊ីដ្រុកស៊ីអេតុកស៊ី) អេទីល] -៤-ហ្វេនីលពីពេរីឌីន-៤-អាស៊ីដកាបុកស៊ីលិក អេទីលអេស្ទែរ)

ហ្វេរ៉ូអ៊ីន (ឌីអាសេទីលមរ៉ហ្វីន)

ហ្វូរេទីឌីន (១-(២ - តេត្រាអ៊ីដ្រូហ្វូហ្វូរីឡុកស៊ីអេទីល( -៤ហ្វេនីលពីពេរីឌីន-៤-អាស៊ីដកាបុកស៊ីលិកអេទីល អេទែ)

អ៊ីដ្រូ កូដូរ (អ៊ីដ្រូកូដេអ៊ីណូន)

អ៊ីត្រូមរ៉ហ្វីណុល (១៤-អ៊ីដ្រុកស៊ីឌីអេដ្រូមរ៉ហ្វីន)

អ៊ីត្រូមរ៉ហ្វូន (ឌីអ៊ីដ្រូមរ៉ហ្វីណុន)

អ៊ីដ្រុកស៊ីប៉េទីឌីន (៤-មេតា-អ៊ីដ្រុកស៊ីហ្វេនីល-១-មេទីលពីពេរីឌីន-៤-អាស៊ីតកាបុកស៊ីលិកអេទីលអេស្ទែរ)

អ៊ីហ្សូមេតាដុន (៦-ឌីមេទីលអាមីណូ-៥-មេទីល-៤ ៤-ឌីហ្វេនីល-៣-អិកហ្សាណូន)

កេតូបេមីដុន(៤-មេតា-អីដ្រុកស៊ីហ្វេនីល-១-មេទីល-៤-ប្រូព្យូនីលពីពេរីឌីន) ※

លើវ៉ូមេទរ៉ហ្វាន* ((-)-៣-មេតុកស៊ី-N-មេទីលមរ៉ហ្វីណាន)

លើវ៉ូម៉ូរ៉ាមីត ((-)-៤-[២-មេទីល-៤-អុកហ្សូ-៣ ៣-ឌីហ្វេនីល-៤-(១-ពៀរ៉ូលីឌីនីល)ប៊ុយទីល] ម័រហ្វូលីន)

អ៊ីវ៉ូហ្វេណាស៊ីលម័រហ្វាន ((-)-៣-អ៊ីដ្រុកស៊ី-អ៊ិន-ហ្វេណាស៊ីលម័រហ្វីណាន)

លីវ័រហ្វាណុល* ((-)៣-អ៊ីដ្រុកស៊ី-អ៊ិន-មេទីលម័រហ្វីណាន)

មេតាហ្សូស៊ីន (២' -អ៊ីដ្រិកស៊ី-២ ៥ ៩-ទ្រីមេទីល-៦ ៧-បង់ហ្សូម័រហ្វាន)

មេតាដូន (៦-ឌីមេទីលអាមីណូ-៤ ៤-ឌីហ្វេនីល-៣-អ៊ិបតាណុន)

មេទីលដេហ្សូរ័ហ្វីន (៦-មេទីល-ដែលតា ៦-ដេអុកស៊ីម័រហ្វីន)

មេទីលឌីអ៊ីដ្រូម័រហ្វីន (៦-មេទីលឌីអ៊ីដ្រូម័រហ្វីន )

១-មេទីល-៤-ហ្វេនីលពីពើរីឌីន-៤-អាស៊ីតកាបុកស៊ីលិក

មេតូប៉ុង (៥-មេទីលឌីអ៊ីដ្រូម័រហ្វីនូន)

ម័រហ្វេរីឌីន (១-(២-ម័រហ្វូរីណូអេទីល)-៤-ហ្វេនីលពីពើរីឌីន-៤-អាស៊ីតកាបុកស៊ីលិក អេទីលអេស្ទែរ)

ម័រហ្វីន

ម័ហ្វីនមេតូប្រូមីត និង ផលិតផលផ្សេងៗទៀតដែលដើមកំណើតពីប៉ិងតាវ៉ាំឡែន នីត្រូសែនម័រហ្វីន

ម័រហ្វីន-N-អុកស៊ីត

មីរ៉ូហ្វីន (មីរីស៊ីលបង់ស៊ីលម័រហ្វីន)

នីកូម័រហ្វីន (៣ ៦-ឌីនីកូទីនីលម័រហ្វីន)

ណ័រឡេវីហ្វាណុល ((-)-៣-អ៊ីដ្រុកស៊ីម័រហ្វីណាន)

ណ័រមេតាដុន (៦-ឌីមេទីលអាមីណូ -៤ ៤-ឌីហ្វេនីល-៣-អ៊ិចហ្សាណូន)

ន័រម័រហ្វីន (ដេមេទីល ម័រហ្វីន)

អាភៀន

អុកស៊ីកូដូន (១៤-អ៊ីដ្រុកស៊ីឌីអ៊ីដ្រូកូដេអ៊ីនូន)

អុកស៊ីម័រហ្វូន (១៤-អ៊ីដ្រុកស៊ីឌអដ្រូម័រហ្វីនន)

ប៉េទីឌីន (១-មេទីល-៤-ហ្វេនីលពីពើរីឌីន-៤-អាស៊ីតកាបុកស៊ីលិកអេទីលអេស្ទែរ)

ហ្វេណាឌុកហ្សូន (៦-ម័រហ្វូលីណូ-៤ ៤-ឌីហ្វេនីល-៣-អិបតានូន)

ហ្វេណំប្រូមីត ( N -(១-មេទីល-២-ពីពើរីឌីណូអេទីល) ប្រូពៀូណានីលីត្រ)

ហ្វេណាហ្សូស៊ីន (២-អ៊ីដ្រុកស៊ី-៥ ៩-ឌីមេទីល-២-ហ្វេនេទីល-៦ ៧-បង់ហ្សូម័រហ្វាន)

ហ្វេណូម័រហ្វាន (៣-អ៊ីដ្រុកស៊ី-N-ហ្វេនេទីលម័រហ្វីណាន)

ហ្វេណូបើរិឌីន (១-(៣-អ៊ីដ្រុកស៊ុ-៣-ហ្វេណីលប្រូពីល)-៤-ហ្វេណីលពីពែរីឌីន-៤-អាស៊ីតកាបុកស៊ីលិកអេទីលអេស្ទែរ)

ពីមីណូឌីន (៤-ហ្វេណីល-១-(៣-ហ្វេណីលអាមីណូប្រូពីល) ពីពែរីឌីន-៤-អាស៊ីតកាបុកស៊ីលិកអេទីលអេស្ទែរ

ប្រូអ៊ីបតាហ្ស៊ីន (១ ៣-ឌីមេទីល-៤-ហ្វេនីល-៤-ប្រូព្យូណកស៊ី អាហ្សាស៊ីក្លូអ៊ិបតាន)

ប្រូពេរីឌីន ( ១-មេទីល-៤-ហ្វេទីលពីពែរីឌីន-៤-អាស៊ីតកាបុកស៊ីលិកអ៊ីសូប្រូពីលអេស្ទែរ)

រ៉ាសេមេទ័រហ្វាន (( ±)-៣-មេតុកស៊ី-N -មេទីលម័រហ្វ៊ីណាន)

រ៉ាសេម័ររ៉ាមីត (±)-៤-(២-មេទីល-៤-អុកហ្សូ-៣ ៣-ឌីហ្វេនីល-៤-(១-ពេរ៉ូលីឌីនីល)ប៊ុយទីល) ម័រហ្វូលីន

រ៉ាសេម័រហ្វាន (±)-៣-អ៊ីដ្រុកស៊ី- N -មេទីម័រហ្វីណាន)

តេបាកុន (អាសេទីលឌីអ៊ីដ្រូកូដេអ៊ីនន)

តេបាអ៊ីន

ទ្រីមេបើរីឌីន (១ ២ ៥-ទ្រីមេទីល-៤-ហ្វេនីល-៤-ប្រូព្យូអុកស៊ីពីពែរីឌីន) ហើយ

វៀលែងតែមានករណីលើកលែងជាពិសេស អ៊ីសូមែរ នៃថ្នាំញៀននៅក្នុងតារាងនេះនៅពេលណាដែលការកើតមាន អ៊ីសូមែរ បែបហ្នឹង អាចកើនមានឡើងនៅតាមការជ្រើសទុកជាមុនផ្នែកគីមីជាលាក់មួយ

អេស្ទែរ និង អេទែ នៃថ្នាំញៀននៅក្នុងតារាងនេះវៀលែងតែមានលេចឡើងនៅក្នុងតារាងផ្សេងនៅពេលណាដែលការកើតមាននៃអេស្ទែរ រឺ អេទែ អាចកើតមានឡើង ។

អំបិលនៃថ្នាំញៀនដែលចុះបញ្ជីក្នុងតារាមួយដោយរាប់បញ្ចូលទាំងអំបិលអេស្ទែរ អេទែ និង អ៊ីសូមែរ ដូចដែលបានផ្តល់ជូនខាងលើនៅពេលណាដែលការកើតមានអំបិលបែបនោះអាចកើតមានឡើង

ដិកស្រ្តូមេតូហ្វង់ ((+ )-៣-មេតុកស៊ី-អិន-មេទីលម័រហ្វីណាន) និង ដិកស្រ្តូហ្វង់ ( (+)-៣-អ៊ីដ្រុកស៊ី-អិន-មេទីលម័រហ្វីណាន) ជាពិសេសមិនរាប់បញ្ចូលទៅក្នុងតារាងនេះទេ ។

បញ្ជីរាយឈ្មោះថ្នាំញៀនដែលបញ្ចូលក្នុងតារាង II

អាសេទីលឌីអ៊ីដ្រូកូដេអ៊ីន

កូដេអ៊ីន (៣-មេទីលម័រហ្វីន)

ដិកស្ត្រូប្រូប៉ុកស៊ីហ្វែន((+)-៤-ឌីមេទីលអាមេណូ-៣-មីទីល-១ ២-ឌីហ្វេនីល-២-ប្រូពុយណុកស៊ីប៊ុយតាន)

ឌីអ៊ីត្រូកូដេអ៊ីន

អេទីលម័រហ្វីន (៣-អេទីលម័រហ្វីន)

ណ័រកូដេអ៊ីន (អិន-ឌីមេទីលកូដេអ៊ីន)

ហ្វូលកូដេអ៊ីន (ម័រហ្វូលីនីលអេទីលម័រហ្វីន) និង

អ៊ីមែររបស់ថ្នាំញៀននៅក្នុងតារាងនេះ នៅពេលណាដែលការកើតមានអ៊ីសូមែរបែបហ្នឹង អាចកើតមានឡើងទៅតាមការជ្រើសទុកជាមុនផ្នែកគីមីជាក់លាក់ វៀលែងតែមានការលើកលែងជាពិសេស ។

អំបិលរបស់ថ្នាំញៀនដែលបានចុះបញ្ជីក្នុងតារាងនេះ ដោយរាប់បញ្ចូលទាំងអំបិល អ៊ីសូមែរដែលបានផ្តល់ជូនខាងលើ នៅពេលណាដែលការកើតមានអំបិលបែបហ្នឹងអាចកើតមានឡើង ។

បញ្ជីការរៀបចំដែលបញ្ចូលក្នុងតារាង III

១- ការរៀបចំរបស់ :

អាសេទីលឌីអ៊ីដ្រូកូដេអ៊ីន

កូដេអ៊ីន

ឌិកស្ត្រូប្រូប៉ុកស៊ីហ្វែន

ឌីអ៊ីដ្រូកូដូអ៊ីន

អេទីលម័រហ្វីន

ណ័រកូដេអ៊ីន

ហ្វូលកូឌីន

នៅពេល

ក- ផ្សំជាមួយវត្ថុធាតុផ្សំមួយ រឺច្រើនទៀតតាមវិធីសាស្ត្របែបនេះ ដែលការរៀបចំគ្មានផលអាក្រក់ដល់ការប្រើ រឺមានតិចតួច ហើយតាមវីធីបែបហ្នឹងថ្នាំញៀនមិនអាចដកចេញយកមកវិញតាមមធ្យោបាយអនុវត្តងាយៗឡើយ រឺក្នុងវិស័យដែលបានបន្តអោយមានគ្រោះថ្នាក់ដល់សុខភាពសារណៈនិង

ខ- ដែលមានបរិមាណថ្នាំញៀនមិនលើសពី ១០០មីលីក្រាមក្នុងកំរិតមួយឯកត្តា និង ដោយមានកំហាប់មិនលើសពី ២.៥ភាគរយ ក្នុងការរៀបចំដែលមិនអាចបំបែកបាន ។

២- ការរៀបចំកូកាអ៊ីន ដែលមានបរិមាណមិនលើសពី ០.១ភាគរយ បានគណនាដូចបាតកូកាអ៊ីន និង ការរៀបចំអាភៀន រឺ ម័រហ្វីន ដែលមានម័រហ្វីន មិនលើសពី ០.២ភាគរយ ដែលបានគណនាដូចបាតម័រហ្វីនដែលគ្មានជាតិទឹកហើយដែលផ្សំជាមួយវត្ថុធាតុមួយរឺច្រើនផ្សេងទៀត តាមវិធីបែបនេះការរៀបចំគ្មានផលគ្រោះថ្នាក់ដល់ការប្រើប្រាស់រឺមានតិចតួចបំផុត ហើយតាមវិធីបែបហ្នឹងថ្នាំញៀនមិនអាចដក

យកមកវិញបានតាមមធ្យោបាយអនុវត្តងាយៗឡើយ រឺក្នុងវិស័យដែលបន្តអោយមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ។

៣- ការរៀបចំ ឌីហ្វេណុកស៊ីលាត ជាដូសរឹង ដែលមានបរិមាណ ឌីហ្វេណុកស៊ីលាតមិនពី ២.៥មីលីក្រាម ដែលបានគណនាដូចបាត និង មានបរិមាណ អាត្រូពីនស៊ុលហ្វាតមិនតិចជាង ២៥មីក្រូក្រាម ក្នុងមួយឯកត្តា គិត ។

៤- Pulvis ipecacuanhae et opii compiositus

អាភៀន ១០ភាគរយជាម្សៅ

ឫស ipecacuanhae 10% ជាម្សៅដែលបានលាយយ៉ាងសប់ល្អជាមួយវត្ថុធាតុដែលជាម្សៅដទៃទៀត ដែលគ្មានផ្ទុកថ្នាំញៀន ៨០%

៥- ការរៀបចំដោយធ្វើឡើងទៅតាមរូបមន្តមួយដែលបានចុះបញ្ជីក្នុងតារាងនេះ និង វត្ថុធាតុដែលលាយចូលក្នុងការរៀបចំនេះ ផ្សំនឹងសារធាតុដែលគ្មានជាតិថ្នាំញៀនណាមួយ ។

បញ្ជីឈ្មោះថ្នាំញៀនដែលបញ្ចូលក្នុងតារាង IV

កញ្ឆា និង ជ័រកញ្ឆា

ដេសូម័រហ្វីន (ឌីអ៊ីដ្រូដេអុកស៊ីម័រហ្វីន)

ហេរ៉ូអ៊ីន (ឌីអាសេទីលម័រហ្វីន)

កេតូបេមីដូន (៤-មេតា-អ៊ីដ្រុកស៊ីហ្វេនីល-១-មេទីល-៤-ប្រូព្យូនីលពីពេរីឌីន) និង

អំបិលនៃថ្នាំញៀន ដែលចុះបញ្ជីក្នុងតារាងនេះនៅពេលណាដែលការកើតមានអំបិលបែបនេះអាចកើតមានឡើង ។